# អន្តរធានកថា

ពណ៌នាអំពីរឿងអន្តរធាន ៥ យ៉ាងនៃពុទ្ធសាសនា

**ជាជំនួយសាលាធម្មវិន័យ**

**ក្នុងកម្ពុជរដ្ឋ**



ខ្ញុំ តិដ្ឋតុ ពុទ្ធសាវង្ស

បោះពុម្ពលើកទី ២

ត្រឹមត្រូវតាមច្បាប់ដើម

ព.ស ២៥៤៤ / ២០០០

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality



លោកយាយឧបាសិកា
ឡៃ . នាង



អ្នកស្រី ជា . ឈាង
(ស.រ.អ)



លោក ជា . សុគុំ



អ្នកស្រី សុភ . អេង



លោកព្រឹទ្ធាចារ្យ
ហេង . កុសល



លោក ចាន់ . យ៉ាន

# អន្តរធានកថា

ពណ៌នាអំពីរឿងអន្តរធាន ៥ យ៉ាងនៃពុទ្ធសាសនា

**មហា តួច-លន់ ជិនវានកោ**

រៀបរៀង

**ព្រះគ្រូសិរីសោភ័ណ កិម-តួរ ចន្ទមង្គលោ**

ក្រុមជំនុំព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ

បានពិនិត្យកែសម្រួល នឹង រៀបរៀងបន្ថែម

**ជាជំនួយសាលាធម្មវិន័យ**

**ក្នុងកម្ពុជរដ្ឋ**


បោះពុម្ពលើកទី ១

ព.ស. ២៤៩៥

ការផ្សាយរបស់បណ្ណាគារ **ជីវងួនហួត**

លេខ ៣០ ស្ពួន វិថីប៉ាស្ទ័រ ខាងកើតផ្សារធំថ្មី ភ្នំពេញ

# អារម្ភកថា

សៀវភៅនេះហៅ អន្តរធានកថាគឺ :

ពណ៌នាអំពីរឿងអន្តរធាន (ការបាត់បង់ ឬសេចក្ដីវិនាសសាបសូន្យ) ៥ យ៉ាង នៃព្រះពុទ្ធសាសនា មានបដិវេធអន្តរធាន (បាត់ការត្រាស់ដឹងនូវមគ្គនឹងផលជាដើម ។ ខ្ញុំបានដកស្រង់ពីក្នុងគម្ពីរជាច្រើនមានគម្ពីរសុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ ពាដិកវគ្គ ត្រង់សម្បសាទនិយសូត្រ នឹងគម្ពីរមនោរថបូរណីអដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាតជាដើមមកប្រែរៀបរៀងបាន កើតជាសៀវភៅច្បាប់នេះឡើង ។

ឯដើមហេតុដែលនាំឱ្យកើតសៀវភៅនេះឡើងនោះ គឺដោយព្រះតេជព្រះគុណ ព្រះគ្រូសិរីសោភ័ណ គិម-តូវ ជាធម្មាចារ្យរបស់ខ្ញុំ. ក្នុងវេលាមួយដែលខ្ញុំទៅជួបនឹងលោក ។ មានថេរដីកាបង្គាប់ឱ្យខ្ញុំប្រែរៀបរៀង. ព្រោះលោកពេញព្រះទ័យចំពោះរឿងនេះ ចង់ឱ្យបានកើតជាសៀវភៅមួយឡើង ដើម្បីទុកជាប្រទីបមួយ សំរាប់ពុទ្ធសាសនិកជនក្នុងកម្ពុជរដ្ឋ អ្នកប្រាថ្នាចង់ជ្រាបនូវការបដិវត្តន៍នៃព្រះពុទ្ធសាសនាក្នុងអនាគតកាល ។ ឯអង្គលោកមានការរវល់មមាញឹក ពុំមានឱកាសល្មមនឹងប្រែរៀបរៀងបាន ។

ខ្ញុំយល់ស្របតាមគំនិតរបស់លោក ហើយក៏ខំព្យាយាមដកស្រង់ប្រែនឹងរៀបរៀងលុះត្រាតែសំរេច. កាលប្រែរៀបរៀងរួចស្រេចហើយខ្ញុំក៏បានយកច្បាប់សំណៅនេះ ទៅប្រគេនលោកពិនិត្យផ្ទៀងផ្ទាត់ឱ្យ. លោកក៏បានទទួលពិនិត្យកែសំរួល នឹងជួយសើរើរៀបរៀងសេចក្ដីបន្ថែមជាថ្មីខ្លះទៀត

ដរាបដល់បានត្រឹមត្រូវម៉ត់ចត់ឡើង ។

ដោយអានុភាពនៃកុសល ដែលកើតអំពីកំលាំងនៃការព្យាយាមដ៏បរិសុទ្ធរបស់ខ្ញុំនេះ ។ សូមឱ្យពុទ្ធសាសនិកក្នុងលោកទាំងឡាយ បានចំរើនលូតលាស់ដុះដាលដោយវឌ្ឍនធម៌ នឹងវិបុលសុខគ្រប់ប្រការ កុំបីឃ្លាតក្លាយទៅជាប្រការដទៃឡើយ ! ។

ថ្ងៃអង្គារ ៣ រោច ខែជេស្ឋ ឆ្នាំរោងចត្វាស័ក $\frac{២៤៩៥}{១៩៥២}$

**មហា គួច_លន់ ជិនវានរោ**

---

**ចិរំ តិដ្ឋតុ ពុទ្ធសាសនំ**

សូមឱ្យព្រះពុទ្ធសាសនាតាំងនៅអស់កាលជាអង្វែង ។

# ឧបត្ថម្ភនិទានកថា

បុព្វហេតុដែលនាំឱ្យយើងទាំងអស់គ្នា ផ្ដើមគំនិតបោះពុម្ពសៀវភៅ **"អន្តរធានកថា"** នេះឡើង ដោយយើងខ្ញុំទាំងអស់គ្នាមានការសោកស្ដាយសៀវភៅនេះជាពន់ពេកណាស់ ពីព្រោះសៀវភៅនេះមានសភាពចាស់ទ្រុឌទ្រោម ដាច់ដាច មានអាយុកាលកន្លះសតវត្សរ៍ទៅហើយនោះ ដូច្នេះដើម្បីការពារព្រះធម៌ជាព្រះពុទ្ធវចនៈរបស់ព្រះសម្មាសម្ពុទ្ធ ឱ្យគង់វង់ ឋិតថេរចិរកាលនោះ ទើបយើងខ្ញុំទាំងអស់គ្នាមូលមតិគ្នាបោះពុម្ពសៀវភៅឡើង ។

ដើមឡើយសៀវភៅ **"អន្តរធានកថា"** នេះត្រូវបានលោកព្រឹទ្ធាចារ្យ **"ហេង កុសល"** ថែរក្សាទុកដាក់ដោយហ្មត់ចត់ជាទីបំផុតទើបខ្ញុំបាទឈ្មោះ **"ចាន់ យ៉ាន"** បានសុំខ្ចីច្បាប់ដើមអំពីលោក មកបោះពុម្ពជាថ្មី ដើម្បីតំកល់ទុកជា សម្បត្តិសាសនាផង និងប្រគេនចែកជូនជាធម្មទាន ចំពោះព្រះសង្ឃ ពុទ្ធបរិស័ទ ក្នុង និង ក្រៅប្រទេស ដោយមិនគិតថ្លៃផង ។

ការបោះពុម្ពសៀវភៅនេះជាថ្មីទៀតសោត គឺយើងខ្ញុំបានរក្សាពាក្យពេចន៍ ខ្លឹមសារ តាមពាក្យដើមទាំងស្រុង ដោយមិនមានកែប្រែអ្វីបន្តិចសោះឡើយ ។

មូលហេតុដែលនាំឱ្យខ្ញុំបានសំរេចជារូបរាងនៃសៀវភៅព្រះធម៌នេះឡើង គឺកើតឡើងពីកំលាំងសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភគាំទ្រ របស់ពុទ្ធបរិស័ទក្នុង និង ក្រៅប្រទេស ជាពិសេសគឺអ្នកស្រី **"ជា លាង"** សព្វថ្ងៃរស់នៅ **"ហ្វីឡាដែលហ្វីយ៉ា"** ស.រ.អា. ដែលឆ្ងាយសែនឆ្ងាយពីទឹកដីកំណើតរបស់អ្នកស្រីយ៉ាងណាក៏ដោយចុះហើយជាទឹកដីនៃប្រទេសដែលមិនគោរពព្រះពុទ្ធសាសនាផងនោះក៏អ្នកស្រីនូវតែមានស្មារតីខ្ពស់ស្រលាញ់ទឹកដីទំនៀមទំលាប់

ប្រពៃណីជាតិ សាសនា ដែលជាទឹកដីបានផ្តល់កំណើតដល់អ្នកស្រី ។

គួរណាស់អ្នកស្រី ដែលកំពុងរស់នៅក្នុងអរិយប្រទេសតែមួយគត់ក្នុងលោក ដែលមានការរីកចំរើនលើគ្រប់វិស័យ ហើយភ្លេចទឹកដី ជាតិ សាសនា របស់អ្នកស្រី ។

ផ្ទុយទៅវិញអ្នកស្រីនៅតែមានស្មារតីគោរពស្រឡាញ់ជាតិ សាសនា មានចិត្តគំនិតជាខ្មែរដដែល ។

ខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា សូមខន្តីអភ័យទោសពីសំណាក់ ព្រះថេរានុថេរៈ និងពុទ្ធបរិស័ទទាំងឡាយ ដែលកំពុងអានសិក្សា រៀនសូត្រសៀវភៅនេះ ប្រសិនបើមានជួបប្រទះឃើញខុសត្រង់ព្យញ្ជនៈ អក្ខរាវិរុទ្ធ ដែលប្រាសចាកច្បាប់ដើមដោយអចេតនាត្រង់កន្លែងណាមួយនេះ សូមខន្តីអភ័យទោសដល់យើងខ្ញុំដោយក្តីអនុគ្រោះ ។

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតឡើងអំពីធម្មទាន ដ៏ថ្លៃថ្លានេះជូនចំពោះ បុព្វការីជនមាន មាតាបិតា ជាដើម ដែលលោកបានចែកឋានទៅហើយនោះ សូមលោកទទួលអនុមោទនា នូវបុណ្យកុសលដែលខ្ញុំបានឧទ្ទិសទៅជូននេះ សូមផលនៃធម្មទាននេះ កើតមានដល់យើងខ្ញុំទាំងអស់គ្នាឱ្យបាននូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស១ សម្បត្តិទេព្វា១ និង ព្រះនិព្វាន១ កុំបី ឃ្លៀងឃ្លាត ឡើយ ។

ថ្ងៃ ៧កើត ខែភទ្របទ ឆ្នាំរោង ទោស័ក ព.ស ២៥៤៤

ត្រូវនឹងថ្ងៃ ៥ ខែ កញ្ញា ឆ្នាំ ២០០០

លោក **ចាន់ យ៉ាន** អតីតប្រធានការិយាល័យធម្មការ និង សាសនា ខ័ណ្ឌឬស្សីកែវ ភ្នំពេញ ។

# មាតិកានុក្រម


| | | |
|---|---|---|
| បណាមគាថា................................................ | ទំព័រ | ១ |
| សេចក្តីពណ៌នាខាងដើម ........................................ | ,, | ១ |
| បដិវេធអន្តរធាន................................................ | ,, | ៣ |
| បដិបត្តិអន្តរធាន ................................................ | ,, | ៧ |
| បរិយត្តិអន្តរធាន................................................ | ,, | ៨ |
| លិង្គអន្តរធាន ................................................ | ,, | ១៤ |
| ធាតុអន្តរធាន................................................ | ,, | ១៨ |
| ធម្មជាតិ ៣ យ៉ាង................................................ | ,, | ៣៥ |
| ធម៌ ៥ យ៉ាងជាអង្គនៃធម្មកថិក................................ | ,, | ៣៨ |
| អទេសនាទិ កិច្ចមានមិនសំដែងធម៌ជាដើម ................ | ,, | ៤០ |
| ធម៌ ៥ យ៉ាងដទៃទៀត................................................ | ,, | ៤១ |
| សាសនារុងរឿងដោយបដិបត្តិបូជា................................ | ,, | ៤២ |

## បណាមគាថា

### នមស្សិត្វាន សម្ពុទ្ធំ ធម្មំ សង្ឃញ្ច ឧត្តមំ
### សាសនន្តរធានម្បិ ភាសិស្សាមានវេនហំ

ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអរហន្តសម្ពុទ្ធ ព្រមទាំងព្រះធម៌នឹងព្រះសង្ឃជារតនៈដ៏ខ្ពស់បំផុតដោយសេចក្ដីគោរព ហើយនឹងពណ៌នានូវសេចក្ដីអន្តរធាននៃព្រះពុទ្ធសាសនា ជាលំដាប់ដូចតទៅនេះ :

## សេចក្ដីពណ៌នាខាងដើម

បើកំណត់ពីត្រឹមក្រោយថ្ងៃដែលព្រះសម្ពុទ្ធជាម្ចាស់ បរិនិព្វានទៅហើយ ព្រះពុទ្ធសាសនា ដែលបានសាយភាយទូទៅក្នុងសកលលោកដរាបមកដល់សម័យបច្ចុប្បន្ននេះ គឺអាស្រ័យដោយសាវ័កទាំងឡាយជាអរិយបុគ្គលខ្លះ ជាបុថុជ្ជនខ្លះ បាននាំគ្នាប្រកាសផ្សាយពុទ្ធសាសនាទៅក្នុងនានាប្រទេសផង បាននាំគ្នាសិក្សារៀនសូត្រស្ដាប់តៗ មកផង ។ ព្រោះហេតុនោះព្រះពុទ្ធសាសនា ក្នុងសម័យខ្លះមានសេចក្ដីថ្កើងរុងរឿងដោយសារពុទ្ធបរិស័ទអ្នកកាន់ប្រព្រឹត្តដោយសេចក្ដីម៉ឺងម៉ាត់ ក៏មានក្នុងសម័យខ្លះ មានសេចក្ដីអាប់ឱនរោយរៀវចុះទៅ ដោយសារពុទ្ធបរិស័ទអ្នកកាន់ប្រព្រឹត្តធូរថយខ្ជិខ្ជា ក៏មាន. ជួនកាលដោយសារពួកជនកាន់សាសនា ដទៃដែលជាប្រតិបក្សនឹងព្រះពុទ្ធសាសនា នាំគ្នាញាំញីកាច់កិនបំបាត់ធ្វើឱ្យសាបសូន្យទៅក៏ មាន. បើពុំដូច្នោះទេ ពុទ្ធបរិស័ទអ្នកកាន់ពុទ្ធសាសនាហ្នឹងឯងមាន

សេចក្តី ប្រតិបត្តិធូរថយរយីករយាកមិនសូវជិតដល់ បណ្តែតបណ្តោយទៅតាម តែបាន មិនអើពើនឹងការសិក្សា នឹងសេចក្តីប្រតិបត្តិ ម្ល៉ោះហើយព្រះពុទ្ធសាសនា ក៏ចេះតែអាប់ឱនដុនដាបសាបរលាបបាត់បន្តិចម្តង ៗ ដរាបដល់សោះសូន្យ ។

ឯធម៌នឹងវិន័យជាតួនៃព្រះពុទ្ធសាសនាទាំងមូល ដែលត្រូវអន្តរធានបាត់បង់សាបសូន្យទៅជាលំដាប់លំដោយគ្នា តាមថ្នាក់នៃគុណធម៌ជាន់ខ្ពស់នឹងជាន់ទាបដែលហៅថា អន្តរធាននោះ មានសំដែងទុកក្នុងគម្ពីរមនោរថបូរណីអដ្ឋកថា នៃគម្ពីរអង្គុត្តរនិកាយ មាន៥ យ៉ាងគឺ :

**១. បដិវេធអន្តរធាន[១] បាត់ការត្រាស់ដឹង**

**២. បដិបត្តិអន្តរធាន បាត់សេចក្តីប្រតិបត្តិ**

**៣. បរិយត្តិអន្តរធាន បាត់ព្រះបរិយត្តិ (ព្រះត្រៃបិដក)**

---

[១] ហៅថា អធិគមអន្តរធាន វិញក៏បាន ។ កន្លែងខ្លះលោករៀងមាតិកាដូច្នេះវិញថា បរិយត្តិអន្តរធាន, បដិបត្តិអន្តរធាន, បដិវេធអន្តរធាន, ឯក្នុងទីនេះបានជាលោករៀងដូច្នេះ ដើម្បីកំណត់ឱ្យដឹងនូវដំណើរនៃពុទ្ធសាសនា ដែលត្រូវសាបសូន្យជាលំដាប់ត១គ្នាទៅ ។

៤. លិង្គអន្តរធាន បាត់ភេទអ្នកបួស

៥. ធាតុអន្តរធាន បាត់ព្រះធាតុ ៕

អធិប្បាយតាមលំដាប់អន្តរធានទាំង ៥ ដែលមានមកហើយក្នុងអតីតខ្លះ ដែលនឹងត្រូវមានតទៅអនាគតខ្លះ ជាសេចក្តីងាយដល់ការពិចារណារបស់ពុទ្ធបរិស័ទ ដូចតទៅនេះ ។

## ១ ) បដិវេធអន្តរធាន

អធិប្បាយ : គុណវិសេសគឺ មគ្គ ៤, ផល ៤, បដិសម្ភិទា[១] ៤, វិជ្ជា[២] ៣, អភិញ្ញា ៦[៣] ទាំងអស់នេះហៅថា បដិវេធ ប្រែថា ធម៌ជាគ្រឿងត្រាស់ដឹងរបស់អរិយបុគ្គល ។ បដិវេធធម៌នោះ កាលដែលនឹងសាបសូន្យ រមែងសាបសូន្យ ចាប់ដើមតាំងអំពីបដិសម្ភិទាទៅ បើរាប់ពីត្រឹមថ្ងៃដែលព្រះពុទ្ធបរិនិព្វានកន្លងទៅចំនួនជា ១.០០០ ឆ្នាំ អរិយបុគ្គលទាំងឡាយមិនអាចនឹងញ៉ាំងបដិសម្ភិទាឱ្យកើតបានឡើយ, អាចឱ្យកើតបានតែត្រឹម

---

[១] អត្ថប្បដិសម្ភិទា ១, ធម្មប្បដិសម្ភិទា ១ , និរុត្តិប្បដិសម្ភិទា ១, បដិភាណប្បដិសម្ភិទា១ ។

[២] បុព្វេនិវាសានុស្សតិញ្ញាណ ១, ចុតូបបាតញ្ញាណ១, អាសវក្ខយញ្ញាណ ១ ។

[៣] ឥទ្ធិវិធញ្ញាណ ១ , ចេតោបរិយញ្ញាណ ១, បុព្វេនិវាសសានុស្សតិញ្ញាណ ១, សត្ថាន់ ចុតូបបាតញ្ញាណ ១, អាសវក្ខយញ្ញាណ ១ ។

អភិញ្ញា ៦ ។ លំដាប់កាលកន្លងពីនោះទៅ អរិយបុគ្គលទាំងឡាយមិនអាចនឹងញ៉ាំងអភិញ្ញា ៦ នោះឱ្យកើតបានទៀតឡើយ. អាចឱ្យកើតបានត្រឹមតែវិជ្ជា ៣ ប៉ុណ្ណោះ ។ ចំណេរកាលដែលកន្លងជាលំដាប់ទៅ អរិយបុគ្គលទាំងឡាយមិនអាចនឹងញ៉ាំង វិជ្ជា ៣ នោះឱ្យកើតបានទៀតឡើយគឺពួកព្រះអរហន្តដែលបានលុះនូវបដិសម្ភិទា ៤ ក្តី បានត្រឹមអភិញ្ញា ៦ ក្តីបានត្រឹមវិជ្ជា ៣ ក្តី លោក បរិនិព្វានបាត់បង់អស់ទៅហើយ. នៅតែព្រះអរហន្តជាសុក្ខវិបស្សកៈ ។

ចំណេរកាលកន្លងជាលំដាប់ទៅទៀត ពួកព្រះអរហន្តជាសុក្ខវិបស្សកៈបរិនិព្វានបាត់បង់អស់ទៅហើយ. នៅតែអរិយបុគ្គលមានអនាគាមិបុគ្គលជាដើម ។ អំណើះកាលកន្លងទៅ អនាគាមិបុគ្គល ក៏បាត់បង់ អស់ទៅទៀត នៅតែអរិយបុគ្គលមានសកទាគាមិបុគ្គលជាដើម ។ អំណើះកាលកន្លងពីនោះទៅទៀត សកទាគាមិបុគ្គលក៏បាត់បង់អស់ទៅ. នៅតែសោតាបន្នបុគ្គល បើពួកលោកជាសោតាបន្នបុគ្គល មាននៅដរាបណា បដិវេធធម៌ក៏មិនទាន់ឈ្មោះថា អន្តរធានទៅដរាបនោះដែរ ។ លុះតែបុគ្គលដែលបានដល់នូវសោតៈ មានក្នុងកាលជាខាងក្រោយគេបំផុត នោះអស់ជីវិតទៅហើយ ក្នុងលោកនេះមិនមានបុគ្គលណាមួយបានដល់នូវ សោតៈទៀតទេបដិវេធធម៌ ទើបឈ្មោះថា អន្តរធានសាបសូន្យទៅក្នុងកាលនោះឯង ។

ន័យមួយទៀត ក្នុងភិក្ខុនីខន្ធកវណ្ណនាវិន័យ លោកពោលថា បដិវេធ

ធសទ្ធម្ម នឹងឋិតនៅដរាបដល់គ្រប់ ៥.០០០ វស្សាគឺឋិតនៅ ដោយសារ អរហន្តបដិសម្ភិទា ១ ពាន់ឆ្នាំ, ដោយសារសុក្ខវិបស្សក: ១ ពាន់ឆ្នាំ, ដោយសារអនាគាមិ ១ ពាន់ឆ្នាំ ដោយសារសកទាគាមី ១ ពាន់ឆ្នាំ ដោយសារសោតាបន្ន ១ ពាន់ឆ្នាំ ។

ក្នុងអដ្ឋកថាទីឃនិកាយ បាដិកវគ្គ ត្រង់សម្បសាទនីយសូត្រលោក ពោលថា បដិវេធសទ្ធម្ម នឹងឋិតនៅដរាបដល់គ្រប់ ៥ ពាន់វស្សាដូចគ្នា តែផ្សេងគ្នាខ្លះដោយឈ្មោះព្រះសទ្ធម្ម គឺឋិតនៅ ដោយបដិសម្ភិទា ១ ពាន់ឆ្នាំ ដោយអភិញ្ញាប្រាំមួយ ១ ពាន់ឆ្នាំ, ដោយវិជ្ជាបី ១ពាន់ឆ្នាំ, ដោយសុក្ខ វិបស្សក:១ពាន់ឆ្នាំ, ដោយបាតិមោក្ខ ១ ពាន់ឆ្នាំ, ឯព្រះសទ្ធម្មឈ្មោះថាអួន ថយរៀវរោយចុះទៅ ចាប់តាំងអំពីបច្ឆិមកបុគ្គល ត្រាស់ដឹងនូវសច្ចធម៌ ហើយធ្វើមរណកាលទៅ ។

ក្នុងអដ្ឋកថាសំយុត្តនិកាយ លោកពោលថា ភិក្ខុទាំងឡាយសម្រេច បដិសម្ភិទាបាន មានតែក្នុងបឋមពោធិកាល[១] កន្លងកាលពីនោះមកមិន

---

[១] បើរាប់ពីត្រឹមវស្សាដែលបានត្រាស់ ទៅទល់នឹងវស្សាដែលបរិនិព្វានត្រូវជា ៤៥ វស្សា ។នេះ ចែកចេញជា ៣ ពោធិកាលគឺ ១៥ វស្សាខាងដើមហៅថាបឋមពោធិកាល, ១៥វស្សាកណ្ដាលហៅ ថាមជ្ឈិមពោធិកាល, ១៥ វស្សាខាងចុងហៅថា បច្ឆិមពោធិកាល ។

អាចសំរេចបដិសម្ភិទាបានឡើយ សំរេចបានតែត្រឹមអភិញ្ញា ៦ ប៉ុណ្ណោះ. កន្លងកាលខាងក្រោយពីនោះមក ក៏មិនអាចសំរេចអភិញ្ញានោះបានទៀត អាច ឱ្យសំរេចបានត្រឹមតែវិជ្ជា ៣ ប៉ុណ្ណោះ ។ លុះកន្លងមកដល់ឥឡូវ នេះ [១] ភិក្ខុ ទាំងឡាយ មិនអាចសំរេចវិជ្ជា ៣ បានទេ. សំរេចបានតែត្រឹម ធ្វើឱ្យអស់អាសវៈទៅប៉ុណ្ណោះ ។ កាលបើភិក្ខុទាំងឡាយ មិនអាចធ្វើឱ្យ អស់អាសវៈទេ ក៏អាចធ្វើឱ្យសំរេចបានតែត្រឹមថ្នាក់អនាគាមិផល. កាលមិនអាចសំរេចអនាគាមិផលនោះទៀតក៏អាចសំរេចបានត្រឹមថ្នាក់ សកទា គាមិ ផល. កាលមិនអាចសំរេចសកទាគាមិផលនោះទៀត ក៏អាចសំរេចបានត្រឹមថ្នាក់សោតាបត្តិផល អំណើះតពីនោះទៅ សូម្បីសោតាបត្តិផលក៏ ភិក្ខុទាំងឡាយមិនអាចនឹងធ្វើឱ្យសំរេច បានផង ដែរ **ឥតំ បដិវេធអន្តរធាន នាមនេះ** ឯងហៅថាបដិវេធអន្តរធាន បាត់ការត្រាស់ដឹងនូវមគ្គ នឹងផលរបស់អរិយបុគ្គល ។ កាលបើការត្រាស់ដឹងនូវ មគ្គនឹងផលបាត់ហើយ. តទៅមុខនឹងបាត់សេចក្តីប្រតិបត្តិជាលំដាប់គ្នាទៀត ។

---

[១] ពាក្យថា "ឥឡូវនេះ" នេះជាពាក្យដែលអដ្ឋកថាចារ្យលោកពោលក្នុងជំនាន់របស់លោក ។

## ២ ) បដិបត្តិអន្តរធាន

**អធិប្បាយ** : ក្រោយពុទ្ធបរិនិព្វានកន្លងមក ភិក្ខុទាំងឡាយអ្នកបំពេញសេចក្តីប្រតិបត្តិត្រឹមត្រូវម៉ត់ចត់ក្នុងសាសនានេះ ជួនកាលមានច្រើនជួនកាលមានតិច. ព្រោះហេតុនោះ សេចក្តីប្រតិបត្តិនឹងការត្រាស់ដឹងនូវមគ្គនឹងផល មិនសូវមានបរិបូរណ៍ ចេះតែធូរថយខ្សោយចុះទៅជាលំដាប់ ។ ចំណោរកាលតទៅខាងមុខ ភិក្ខុទាំងឡាយ ប្រតិបត្តិធម៌មិនអាច នឹងញ៉ាំងគុណវិសេសគឺ ឈាន. វិបស្សនា. មគ្គនឹងផលឱ្យកើតឡើងបានឡើយ នាំគ្នារក្សាត្រឹមតែបារិសុទ្ធិសីលទាំង៤ មានបាតិមោក្ខសំវរសីលជាដើមប៉ុណ្ណោះ ។

ចំណោរកាលកន្លងពីនោះទៅទៀត ភិក្ខុទាំងឡាយប្រជុំប្រឹក្សាគ្នាថា យើងទាំងឡាយ ខំប្រឹងរក្សាសីលឱ្យបានបរិសុទ្ធពេញលេញល្អ មិនឱ្យមានដាច់ធ្លុះធ្លាយ ឬសៅហ្មង ទាំងបានបំពេញព្យាយាមជារឿយៗ ក្នុងការអប់រំចំរើននូវសមណធម៌ទៀតផង តែយើងទាំងអស់គ្នា ពុំមានអ្នកណាមួយអាចបានសំរេចមគ្គផលអ្វីមួយឡើយ. សម័យឥឡូវនេះមិនមានការត្រាស់ដឹងនូវមគ្គផលទេ ដូច្នេះហើយក៏នាំគ្នារសាយចិត្តរក្សាចតុប្បារិសុទ្ធិសីលដោយខ្ជីខ្ជា ធ្វើឱ្យដាច់ធ្លុះធ្លាយបណ្តោយឱ្យសេចក្តីប្រមាទចូលលុកលុយក្នុងខន្ធសន្តានពេញទីក្រាស់ ដោយសេចក្តីខ្ជិលច្រអូសមិនខំប្រឹងសិក្សាស្វាធ្យាយធម្មវិន័យ មិនដាស់តឿនគ្នា មិនពោលក្រើនរំលឹកទូន្មានដល់គ្នានឹងគ្នា.មិន

មានសេចក្តីរង្កៀសសង្ស័យអ្វីតិចតួចឡើយ ។ ចាប់ដើមពីត្រឹមនោះទៅ ភិក្ខុទាំងឡាយនោះ នាំគ្នាញ៉ាំញីនូវខុទ្ទានុខុទ្ទកសិក្ខាបទទាំងឡាយដោយលំដាប់ដរាបដល់ ធ្វើឱ្យត្រូវអាបត្តិបាចិត្តិយៈខ្លះ ថុល្លច្ច័យខ្លះ សង្ឃាទិសេសខ្លះឥតមានសេចក្តី ខ្មាសឬខ្លាចញញើតចំពោះទោសតូច-ធំឡើយ ។ កន្លងកាលពីនោះទៅទៀត ភិក្ខុទាំងឡាយនៅរក្សាបានតែបារាជិកាបត្តិ ៤ ប៉ុណ្ណោះ ។ បើមានភិក្ខុចំនួន ជា ១ រយរូបក្តី ១ ពាន់រូបក្តី ដែលរក្សាបារាជិក ៤មាននៅដរាបណាដរាបនោះ សេចក្តីប្រតិបត្តិឈ្មោះថានៅឋិតថេរ មិនទាន់អន្តរធានសាបសូន្យទៅទេ ដរាបណា បច្ឆិមភិក្ខុ គឺភិក្ខុក្នុងជំនាន់ខាងក្រោយរក្សាបារាជិក ៤ នោះមិនបាន ដោយធ្វើឱ្យបែកធ្លាយដាច់សីលទៅ ឬក៏ធ្វើមរណកាលទៅ, ដរាបនោះ សេចក្តីប្រតិបត្តិទើបឈ្មោះថា អន្តរធានបាត់បង់ទៅពិតប្រាកដ **ឥឡូវ បដិបត្តិអន្តរធានំ នាម** នេះឯងហៅថាបដិបត្តិអន្តរធាន បាត់សេចក្តី ប្រតិបត្តិកាលបើសេចក្តីប្រតិបត្តិបាត់ហើយ តទៅមុខនឹងបាត់បរិយត្តិ គឺព្រះត្រៃបិដកជាលំដាប់គ្នាទៀត ។

## ៣ ) បរិយត្តិអន្តរធាន

**អធិប្បាយ** : សាសនារបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ ដែលទ្រង់ប្រតិស្ឋានទុកក្នុងឋានៈជាសាស្ត្រាចារ្យប្រៀនប្រដៅសត្វទាំងឡាយ ក្នុងបច្ឆិមកាលក្រោយពុទ្ធបរិនិព្វានមក ជាតំណាងព្រះអង្គនោះ មានអាយុតាំងនៅអស់

កាលជាអង្វែងឆ្នាំ ទើបអន្តរធានសាបសូន្យទៅ ។ ឯសាសនានេះដែលនឹងតាំងនៅបាន អាស្រ័យដោយបរិយត្តិ គឺព្រះត្រៃបិដកជាប្រមាណ. បើបរិយត្តិឋិតនៅដរាបណា សាសនា ក៏អាចតាំងនៅបាន ដរាបនោះ. បើបរិយត្តិវិនាសសាបសូន្យដោយហេតុណាមួយហើយ សាសនាក៏នឹងតាំងនៅដោយឯកឯងមិនបានឡើយ គង់តែវិនាសសាបសូន្យទៅដែរ ។ ឯបរិយត្តិដែលនឹងសាបសូន្យទៅនោះ ដូចសេចក្តីពណ៌នាតទៅនេះ :

បាលីព្រមទាំងអដ្ឋកថា ក្នុងពុទ្ធវចនៈព្រះត្រៃបិដក ឋិតនៅដរាបណាដរាបនោះ បរិយត្តិ ក៏ឈ្មោះថានៅមានពេញបរិបូណ៌ មិនទាន់សាបសូន្យនៅឡើយ ។ ចំណោរកាលទៅខាងមុខ នៅក្នុងសម័យកើតកលិយុគ គឺសម័យដែលប្រទេសនានាក្នុងលោកប្រកបដោយទោសវិបត្តិ វិបរិតផ្សេងៗ ព្រះរាជាទាំងឡាយ ដែលគ្រប់គ្រងពិភពលោកផ្ទៃក្រោមនេះ ជាអធម្មិករាជគឺជាស្តេចមិនប្រកបដោយទសពិធរាជធម៌ ។ កាលបើស្តេចទាំងឡាយជាអធម្មិករាជ. ឥស្សរជនទាំងឡាយមានរាជមហាមាត្យជាដើម ដរាបដល់ប្រជាជន ដែលនៅអាស្រ័យក្នុងស្រុក និគមជនបទ. រាជធានី ក៏សុទ្ធតែជាអធម្មិកជនដូចគ្នាទាំងអស់ ។ ដោយហេតុតែមនុស្សទាំងឡាយមាន ព្រះរាជាជាដើមនោះ ជាអ្នកប្រព្រឹត្ត តែធម៌លាមកអាក្រក់នៅក្នុងខន្ធសន្តានភ្លៀងក៏មិនបង្អុរធ្លាក់ចុះមក ដោយស្រួលស្រូវសន្ទូងក្នុងស្រែទាំងពូងគ្រប់ទី

តំបន់ ក៏វិនាសខូចខាតអស់ទៅព្រោះតែភ្លៀងធ្លាក់ចុះមកពុំគ្រប់គ្រាន់នោះ ឯងហេតុនោះ ប្រទេសទាំងឡាយក៏នឹងកើតទុរ្ភិក្សអត់ឃ្លាន ពួកមនុស្ស រង ទុក្ខវេទនាលំបាក ពន់ប្រមាណ ក្នុងការស្វែងរកចំណើអាហារយកមក បរិភោគចំអែតផ្ទៃ ។ ទាយកទាយិកាទាំងឡាយ មិនអាចនឹងប្រគេន ចតុប្បច្ច័យដល់ភិក្ខុសង្ឃដូចពេលមុន ៗ បាន ។ ម្ល៉ោះហើយភិក្ខុទាំងឡាយ កាលបើខ្វះខាតលំបាកដោយបិណ្ឌបាតប្បច្ច័យហើយ ក៏មិនអាចនឹងទំនុក បំរុងសង្គ្រោះដល់ពួកអន្តេវាសិត ( សិស្ស) អ្នករៀនសូត្របានតទៅទៀត ។ កាលបើយប់នឹងថ្ងៃចេះតែកន្លងទៅ ៗ ពួកភិក្ខុអ្នកទ្រទ្រង់បរិយត្តិ នៅ ទ្រទ្រង់ចាំតែត្រឹមបាលី មិនអាចនឹងទ្រទ្រង់ចេះចាំសេចក្តីអធិប្បាយបាន ផង ។ ចំណោរកាលតទៅមុខទៀត សូម្បីតែបាលី ក៏ភិក្ខុទាំងឡាយមិនអាច នឹងទ្រទ្រង់ចេះចាំបានទៀត ដោយហេតុនោះបរិយត្តិក៏ចេះតែសាបសូន្យ បាត់ទៅជាលំដាប់ ។ ឯបរិយត្តិ ដែលនឹងសាបសូន្យទៅនោះ គឺសាប សូន្យអភិ ធម្មបិដកជាដំបូង, បន្ទាប់ពីនោះទៅ សាបសូន្យសុត្តន្តបិដក, បន្ទាប់ពីនោះ ទៅទៀត សាបសូន្យវិន័យបិដកជាលំដាប់គ្នា ។

បិដកនីមួយៗ សាបសូន្យតាំងអំពីគម្ពីរខាងចុងដរាបដល់គម្ពីរខាង ដើមគឺអភិធម្មបិដក សាបសូន្យគម្ពីរមហាបដ្ឋានខាងចុងជាដំបូង, តពី នោះទៅសាបសូន្យគម្ពីរយមកៈ តពីនោះទៅសាបសូន្យគម្ពីរកថាវត្ថុ តពី

នោះទៅសាបសូន្យគម្ពីរបុគ្គលបញ្ញត្តិ. តពីនោះទៅសាបសូន្យគម្ពីរធាតុកថា. តពីនោះទៅសាបសូន្យគម្ពីរវិភង្គ. តពីនោះទៅសាបសូន្យគម្ពីរធម្មសង្គណីដោយលំដាប់គ្នា ។ ទោះបីអភិធម្មបិដក សាបសូន្យបាត់បង់ទៅហើយក៏ដោយ សាសនាក៏អាចតាំងនៅបានតទៅទៀត ដោយអាស្រ័យបិដកពីរគឺវិន័យបិដកនឹងសុត្តន្តបិដក ដែលនៅគង់វង់នៅឡើយ ។ កាលបើអភិធម្មបិដកសាបសូន្យទៅហើយ តទៅមុខនឹងត្រូវសាបសូន្យសុត្តន្តបិដកទៀត. ឯសុត្តន្តបិដក នឹងសាបសូន្យគម្ពីរអង្គុត្តរនិកាយជាដំបូង គឺចាប់សាបសូន្យតាំងពីឯកាទសកនិបាត ដរាបដល់ឯកនិបាត ។ កាលបើគម្ពីរអង្គុត្តរនិកាយនោះសាបសូន្យទៅហើយ តទៅនឹងសាបសូន្យគម្ពីរសំយុត្តនិកាយទៀត ឯក្នុងផ្ទៃគម្ពីរសំយុត្តនិកាយដែលនឹងត្រូវសាបសូន្យទៅនោះ គឺចាប់សាបសូន្យពីមហាវគ្គជាដំបូង តពីនោះទៅ សាបសូន្យសឡាយតនវគ្គ. តពីនោះទៅសាបសូន្យខន្ធកវគ្គ តពីនោះទៅសាបសូន្យនិទានវគ្គ តពីនោះទៅសាបសូន្យសគាថវគ្គទៀត ។ កាលបើគម្ពីរសំយុត្តនិកាយសាបសូន្យទៅហើយតទៅនឹងសាបសូន្យគម្ពីរមជ្ឈិមនិកាយទៀត ឯក្នុងផ្ទៃគម្ពីរមជ្ឈិមនិកាយដែលនឹងត្រូវសាបសូន្យទៅនោះគឺចាប់សាបសូន្យពីឧបរិបណ្ណាសកៈជាដំបូង. តពីនោះទៅសាបសូន្យមជ្ឈិមបណ្ណាសកៈតពីនោះទៅសាបសូន្យមូលបណ្ណាសកៈទៀត ។ កាលបើគម្ពីរមជ្ឈិមនិកាយសាបសូន្យទៅ

ហើយ តទៅនឹងសាបសូន្យគម្ពីរទីឃនិកាយទៀត. ឯក្នុងផ្ទៃគម្ពីរទីឃនិកាយដែលត្រូវសាបសូន្យទៅនោះ គឺចាប់សាបសូន្យពីបាដិយវគ្គទៅជាដំបូង. តពីនោះទៅសាបសូន្យមហាវគ្គ. តពីនោះទៅសាបសូន្យសីលក្ខន្ធកវគ្គទៀត ។

កាលបើគម្ពីរទីឃនិកាយ សាបសូន្យបាត់បង់ទៅវេលាណា សុត្តន្តបិដកក៏ឈ្មោះថាសាបសូន្យបាត់បង់ទៅវេលានោះ តែសាសនា អាចតាំងនៅបានដោយអាស្រ័យវិន័យបិដកមួយ ។ ក្នុងសម័យដែលអភិធម្មបិដកនឹងសុត្តន្តបិដក សាបសូន្យទៅហើយ. ភិក្ខុទាំងឡាយក្នុងសាសនានេះ នៅទ្រទ្រង់ចាំបានតែជាតក នឹងវិន័យបិដកប៉ុណ្ណោះ ។ ពួកភិក្ខុអ្នកមានសេចក្ដីខ្មាស ទ្រទ្រង់ចាំបានខាងវិន័យបិដក ឯពួកភិក្ខុអលជ្ជីមិនមានសេចក្ដីខ្មាសជាអ្នកប្រាថ្នាលាភ ល្មោភបច្ច័យ ទ្រទ្រង់ចាំបានតែជាតកម្យ៉ាង ។

កាលបើកន្លងពីនោះទៅ ភិក្ខុទាំងឡាយមិនអាចនឹងទ្រទ្រង់ចាំជាតកបានទៀត ម្ល៉ោះហើយ គម្ពីរជាតកទាំងឡាយ ក៏ត្រូវសាបសូន្យបាត់បង់ទៅ ដោយលំដាប់គ្នា ជាបដិលោម. បណ្ដាគម្ពីរជាតកទាំងអស់ ប៉ែកខាងគម្ពីរវេស្សន្តរជាតកសាបសូន្យជាដំបូង. លំដាប់តទៅសាបសូន្យ គម្ពីរបុណ្ណកជាតក. លំដាប់តទៅទៀត សាបសូន្យគម្ពីរមហានារទជាតក សាបសូន្យគម្ពីរដរាបដល់គម្ពីរ អបណ្ណកជាតក ជាទីបំផុត ។ កាលបើជាតក

ទាំងឡាយអន្តរធានទៅហើយ. ពួកភិក្ខុក្នុងសាសនានេះនៅទ្រទ្រង់តែវិន័យបិដកមួយប៉ុណ្ណោះ ។ លុះចំណេរចេរកាល ទៅខាងមុខវិន័យ បិដកនោះក៏អន្តរធានទៅទៀតគឺ អន្តរធានចាប់តាំងអំពីគម្ពីរទីបំផុតខាងចុងឡើងទៅ គឺគម្ពីរបរិវារៈ អន្តរធានជាដំបូង. តពីនោះទៅ អន្តរធានខន្ធកៈ. ភិក្ខុនីវិភង្គ. មហាវិភង្គ. មាតិកា. បាតិមោក្ខ ដោយលំដាប់គ្នាជាបដិលោម ។ ក្នុងកាលនោះ បរិយត្តិ ក៏ឈ្មោះថាអន្តរ ធានបាត់បង់អស់ទៅគ្មាននៅសល់ឡើយ. តែថាបើមានគាថាប្រកបដោយបាទ ៤ នៅប្រព្រឹត្តទៅក្នុងពួកមនុស្សដរាបណា. ដរាបនោះ បរិយត្តិ ឈ្មោះថា មិនទាន់អន្តរធានបាត់បង់ទៅដែរ. លុះត្រាតែក្នុងកាលណា ដែលមានព្រះ រាជាទ្រង់មានព្រះរាជសទ្ធាជ្រះថ្លា មុតមាំ ក្នុងសាសនា បានត្រាស់បង្គាប់រាជបុរសទាំងឡាយឱ្យនាំយកកហាបណៈ ចំនួន មួយសែន ដាក់ក្នុងប្រអប់មាស ច្រកក្នុងថង់លើកដាក់លើខ្នងដំរី ហើយឱ្យបរដំរីនោះចេញទៅ ទូងស្គរស្រែកឃោសនាប្រកាស ប្រាប់មហា ជនគ្រប់ផ្លូវនានា ក្នុងផ្ទៃព្រះរាជធានីថា "បើអ្នកណាចេះ ចាំគាថាប្រកប ដោយបាទទាំង ៤ ដែលព្រះពុទ្ធអង្គទ្រង់សំដែងទុក មក សូមឱ្យអ្នកនោះចូល មកទទួលយកកហាបណៈចំនួនមួយសែននេះចុះ. យ៉ាងនេះ ដរាប ដល់គ្រប់ បីដង បើនៅតែមិនមានអ្នកណាចូលមកទទួល យកទេ ហើយរាជបុរស ទាំងឡាយក៏នាំយកថង់កហាបណៈនោះ

ត្រលប់ចូលទៅ កាន់ព្រះរាជវាំងវិញ. ក្នុងកាលនោះ បរិយត្តិ ទើបបាន ឈ្មោះថាអន្តរធានបាត់បង់ទៅពិតប្រាកដ ។ **ឥឡូវ បរិយត្តិអន្តរធាន នាម** នេះឯងហៅថា បរិយត្តិអន្តរធានបាត់ បរិយត្តិ (ការសិក្សាព្រះត្រៃបិដក) កាលបើ បរិយត្តិបាត់ហើយតទៅមុខនឹងបាត់ភេទអ្នកបួសជាលំដាប់គ្នាទៀត ។

## ៤ ) លិង្គអន្តរធាន

**អធិប្បាយ** : ចំណេរកាលទៅខាងមុខ ពួកភិក្ខុជាសមណសក្យបុត្រ ក្នុងពុទ្ធសាសនានេះ ជាអលជ្ជីមិនមានសេចក្តីអៀនខ្មាសប្រព្រឹត្តិខុសប្លែងៗ ឃ្លាតចាកគន្លងធម្មវិន័យ ពុំត្រឹមត្រូវតាមមាត្រាក្រមក្រឹត្យពុទ្ធប្បញ្ញត្តិ ដែល មានត្រាទុកក្នុងវិន័យបិដក, មានឥរិយាបថទាំង ៤ គឺដើរ, ឈរ, អង្គុយ, ដេក នឹងការប្រើប្រាស់នូវវត្ថុផ្សេងៗ ពុំសមរម្យទៅតាមសមណសារូប ពុំគួរជា គ្រឿងសមណបរិភោគ ដូចជាការស្លៀកដណ្តប់ស្បង់ចីពរ, ការកាន់បាត្រ, ការ បត់ចូលលាចេញនូវដៃ នឹងកិរិយាងាកបែរមើលឆ្វេង ស្តាំមុខក្រោយជាដើម ទៅជាឥតសណ្តាប់ធ្នាប់រយីករយាក មិនមានបរិមណ្ឌល ខ្ជីខ្ជាច្រងេងច្រងាង ឃ្មើសឃ្មងច្រឡើសបើស. ដាក់បាត្រត្រង់ចុងដើមដៃកាន់ដើរទៅ ដូចជាពួក សមណនិគ្រន្ថកាន់បាត្រផ្លែឃ្លោកដូច្នោះឯង មិនជាទីនាំមកនូវសេចក្តីជ្រះថ្លា ដល់ពួកទាយកទាយិកា អ្នកស្រុកនិគមជនបទផ្សេងៗ ។ បើទុកជាដូច្នោះភេទ បព្វជិតឈ្មោះថា អន្តរធានទៅដោយហេតុត្រឹមប៉ុណ្ណោះក៏ទេដែរ. តែលុះកាល កន្លងទៅមុខ ពួកភិក្ខុឈប់ដាក់បាត្រត្រង់ចុងដើមដៃវិញ ហើយត្រលប់ជាយួរ

ដោយដៃ ឬក៏ដាក់សង្រែកយួរដើរទៅវិញ. ឯស្បង់នឹងចីពរ ក៏មិនធ្វើជនកម្ម (ជ្រលក់) ឱ្យមានពណ៌សម្បុរ សមគួរជាគ្រឿងសមណបរិក្ខារឡើយ បែរជាជ្រលក់ធ្វើឱ្យមានពណ៌ដូចជាពណ៌ឆ្អឹងឱដ្ឋ. ព្យាយាមរកគ្រឿងបរិក្ខារផ្សេងៗ មករចនាតុបតែងរាងកាយច្រើនបែប ច្រើនយ៉ាង ទៅតាមទំនើងចិត្ត ដែលជាវិធីបែបផែនរបស់គ្រហស្ថអ្នកបរិភោគកាមគុណ ហើយមានចិត្តជាប់ជំពាក់ក្នុងវត្ថុទាំងនោះដែលជាហេតុបញ្ឆោរកាមតណ្ហាឱ្យរឹងរិតតែចំរើនដុះដាលពុះពោរខ្លាំង ឡើង ៗ នឹងជាគ្រឿងធ្វើចិត្ត ឱ្យទទឹកជោគជាំក្រាស់ចូនទៅដោយកាមរោគ មិនសូវរវល់អើពើយកចិត្តទុកដាក់នឹងកិច្ចវត្ត កិច្ចសិក្សាស្វាធ្យាយ ប្រតិបត្តិធម៌វិន័យឡើយ ។

កាលកន្លងទៅមុខទៀត សូម្បីតែកិច្ចជ្រលក់ត្រៃចីវរក៏ឥតមានធ្វើឡើយ.ភិក្ខុទាំងឡាយគ្រាន់តែយកសំពត់មកកាត់ជាយ នឹងដាក់ក្រវិលក្តុំធ្វើឱ្យជារបស់គួរប៉ុណ្ណោះ ក៏នាំគ្នាស្លៀកដណ្តប់ប្រើប្រាស់ទៅ. តពីនោះទៅទៀត. ភិក្ខុទាំងឡាយ លែងដាក់ក្រវិលក្តុំ ទាំងមិនបានធ្វើឱ្យជារបស់គួរ ហើយក៏ចេះតែនាំគ្នាស្លៀកដណ្តប់ប្រើប្រាស់ទៅ ។ កន្លងកាលទៅមុខទៀត. កិច្ចទាំងពីរយ៉ាង ខាងលើនេះ ភិក្ខុទាំងឡាយ ក៏លះបង់ចោលលែងធ្វើ គ្រាន់តែយកសំពត់មកកាត់ជាយ រួចហើយក៏ប្រើប្រាស់ស្លៀកដណ្តប់ត្រាច់ចរទៅក្នុងទីផ្សេងៗ ដូចជា សមណបរិព្វាជកដូច្នោះឯង ។

ចំណេរកាលតទៅខាងមុខទៀត ភិក្ខុទាំងឡាយគិតគ្នាថា "ពួកយើងប្រើប្រាស់ចីវរបែបនេះ មានប្រយោជន៍អ្វី នាំឱ្យតែធ្ងន់រយីករយាកលំបាកនឹងដើរ ឬលំបាកប្រកបការងារអ្វីៗ ទាំងអស់" ដូច្នេះហើយក៏ព្រមព្រៀងមូលមតិគ្នាលះបង់ចីវរចោលទៅ. នាំគ្នាយកកំណាត់សំពត់កាសាវៈតូចៗ មកចងកខ្លះចងកដៃខ្លះ ចងទំលាក់ចុះតាមចុងសក់ខ្លះសៀតនឹងត្រចៀកខ្លះតែប៉ុណ្ណោះ ក៏គេនាំគ្នាសំគាល់ថាជាភេទបព្វជិតពុទ្ធសាសនាក្នុងសម័យនោះ ។ ឯពួកបព្វជិត ទាំង នោះមានភរិយាបុត្រធីតាដូចគ្រហស្ថ, ក៏តាំងនាំគ្នាប្រកបការងារកសិកម្មភ្ជួររាស់សាបព្រោះដកស្ទូងរករបរផ្សេងៗ ចិញ្ចឹមជីវិតជាមួយនឹងគ្រួសារ ដូចគ្រហស្ថទាំងពួងមិនមានស្ថានត្រង់ណាដែលប្លែកអំពីគ្រហស្ថឡើយឃើញប្លែក អំពីគ្រហស្ថតែត្រង់មានកំណាត់សំពត់កាសាវៈតូចៗចងកជាដើមប៉ុណ្ណោះឯង ។ បែកខាងសេចក្តីប្រព្រឹត្តិប្រតិបត្តិ ក៏ឃ្លៀងឃ្លាតចាកធម៌វិន័យទាំងអស់គ្រាន់តែមានភេទជាអ្នកបួសដោយឥតមានក្លែងក្លាយ ឬរង្កៀសសង្ស័យឡើយ ព្រោះបានទទួលផ្នួសអំពីសំណាក់គ្រូអាចារ្យតមកប៉ុណ្ណោះ ។ ក្នុងកាលនោះពួក ទាយកទាយិកា កាលនឹងធ្វើទក្ខិណាទាន ក៏បានឱ្យដល់ពួកអ្នកបួសទាំងនោះ តែចិត្តឧទ្ទិសចំពោះសង្ឃពិតៗ ។ សង្ឃគតាទក្ខិណាទានបែបនេះ របស់ពួកជនក្នុង សម័យនោះ ជាគុណជាតិថ្លៃថ្លាមានផលច្រើនជាអនេក ត្បិតមានព្រះពុទ្ធដិកា ដែលព្រះបរមគ្រូទ្រង់ត្រាស់

នឹងព្រះអានន្ទពុទ្ធុបដ្ឋាកជាភស្តុតាងថា : **ភវិស្សន្តិ ខោ បនានន្ទ អនាគតមទ្ធានំ គោត្រភុនោ កាសាវកណ្ឋា ទុស្សីលា បាបធម្មា តេសុ ទុស្សីលេសុ សង្ឃំ ឧទ្ទិស ទានំ ទស្សន្តិ តទា បនាហំ អានន្ទ សង្ឃគតំ ទក្ខិណំ អសង្ខេយ្យំ អប្បមេយ្យំ វទាមីតិ** ។ "ម្នាលអានន្ទ គោត្រភូសង្ឃ ដែលមានសំពត់កាសាវៈ (សំពត់ជ្រលក់ដោយទឹកអម្ចត់) ចងនឹងក ជាសង្ឃទ្រុស្តសីល មានធមិដ៏លាមក នឹងមានប្រាកដក្នុងកាលជាអនាគត, ទាយក ទាយិកា ទាំងឡាយ ថ្វាយទានក្នុងគោត្រភូសង្ឃទ្រុស្តសីលទាំងនោះឧទ្ទិសចំពោះសង្ឃ ម្នាល់អានន្ទ តថាគតពោលថាសង្ឃគតា ទក្ខិណាទាន ក្នុងកាលនោះឯង ជាគុណ ជាតិមានផលរាប់មិនបានប្រមាណមិនអស់ឡើយ " ។

លុះចំណេរកាលតពីនោះទៅទៀត អ្នកបួសពួកនោះមានការរបររកចិញ្ចឹមជីវិតនឹងគ្រួសារផ្សេងៗ កាន់តែច្រើនឡើង ៗ ទើបប្រឹក្សាគ្នាថា "សំពត់កាសាវៈតូចៗនេះ មានប្រយោជន៍អ្វីដល់ពួកយើង នាំឱ្យតែយឺតយូរដំណើរការងារប៉ុណ្ណោះ " ដូច្នេះហើយ ក៏ព្រមព្រៀងគ្នាដកកំណាត់សំពត់សាកាវៈតូចៗនោះ គ្រវែងចោលទៅក្នុងព្រៃអស់ទៅ ។ ក្នុងសម័យនោះ ភេទបព្វជិតក្នុងព្រះពុទ្ធសាសនានេះឈ្មោះថាអន្តរធាន បាត់បង់ទៅត្រឹមនោះពិតប្រាកដ ។

**ឥទំ លិង្គអន្តរធានំ នាម** នេះឯងហៅថាលិង្គអន្តរធាន បាត់ភេទអ្នកបួស. កាលបើភេទអ្នកបួសបាត់ហើយ តទៅមុខនឹងបាត់ព្រះធាតុរបស់ព្រះ សម្មាសម្ពុទ្ធជាលំដាប់គ្នាទៀត ។

## ៥ ) ធាតុអន្តរធាន

**អធិប្បាយ :** ការអន្តរធានសាបសូន្យទៅ នៃព្រះបរមធាតុទាំងឡាយ គប្បីជ្រាបសេចក្តីដូចតទៅនេះ បរិនិព្វាន មាន ៣ យ៉ាងគឺ **កិលេសបរិនិព្វាន** (កាលរលត់ទៅនៃកិលេស) ១ **ខន្ធបរិនិព្វាន** (ការរលត់ទៅនៃខន្ធ) ១ **ធាតុបរិនិព្វាន** (ការរលត់ទៅនៃព្រះធាតុ) ១ ។

បណ្តាបរិនិព្វានទាំង ៣ យ៉ាងនោះ កិលេសបរិនិព្វាន មានរួចមកហើយ នៅលើរតនបល្ល័ង្ក ក្រោមពោធិព្រឹក្ស ត្រង់ពុទ្ធគយា ។ ខន្ធបរិនិព្វាន មានរួចមកហើយដែរ នៅក្រោមលង្វែកសាលព្រឹក្សទាំងគូក្នុងសាលវនោទ្យាន នៃមល្លក្សត្រ ជិតក្រុងកុសិនារា ឯធាតុបរិនិព្វាន នឹងមានក្នុងអនាគតកាល ។ ធាតុបរិនិព្វាននោះមានបការៈយ៉ាងណា ? ព្រះធាតុទាំងឡាយ របស់ព្រះបរមគ្រូ កាលបើមិនបានទទួលគ្រឿងសក្ការបូជានឹងសេចក្តីរាប់អានអំពីសំណាក់មហាជនក្នុងទីណា ក៏អណ្តែតត្រសែតចាកទីនោះ ទៅកាន់ទីដែលមានមហាជនធ្វើសក្ការបូជាគោរពរាប់អានដោយអំណាចកំលាំងព្រះពុទ្ធាធិដ្ឋាន ។ លុះ

ចំណោរកាលកន្លងទៅព្រះបរមធាតុទាំងឡាយ ក៏ពុំមានគ្រឿងសក្ការបូជា នឹងសេចក្តីរាប់អានអំពីសំណាក់មហាជនគ្រប់ទីតំបន់ ។ កាលបើដល់ពេលទៀបនឹងសាបសូន្យ. ព្រះបរមធាតុទាំងឡាយ ដែលប្រតិស្ឋាននៅក្នុងតម្ពបណ្ណិទ្វីប ( កោះលង្កា ) បានមូលផ្តុំគ្នាអណ្តែតត្រសែតទៅកាន់មហាចេតិយ រួចទើបអណ្តែតចេញចាកមហាចេតិយនោះទៅកាន់នាគទីបចេតិយ អណ្តែតចាកចេញនាគទីបចេតិយនោះទៅកាន់មហាពោធិបល្ល័ង្ក ។ ឯព្រះបរមធាតុទាំងឡាយដទៃទៀត ដែលប្រតិស្ឋាននៅក្នុងពិភពនាគក្តីក្នុងទេវលោកក្តី ក្នុងព្រហ្មលោកក្តីឬក្នុងទីណាៗក្តី ក៏អណ្តែតត្រសែតវិលមកកាន់មហាពោធិបល្ល័ង្កទាំងអស់ ។ ព្រះបរមធាតុតូចៗ សូម្បីមានទំហំប៉ុនគ្រាប់ស្ពៃក្តី ក៏ឥតមានវិនាសបាត់ទៅណាសោះឡើយ ។ ព្រះបរមធាតុទាំងអស់នោះ កាលបើអណ្តែតត្រសែតចាកទីផ្សេង ៗ មក ជួបជុំសមោធានផ្តុំគ្នា នៅលើមហាពោធិបល្ល័ង្ក ទៀបគល់មហាពោធិព្រឹក្សហើយ ក៏និម្មិតជាព្រះពុទ្ធរូប ១ ព្រះអង្គ[១] សំដែងជាសិរីរៈនៃព្រះពុទ្ធពេញលេញប្រកបដោយមហាបុរិសលក្ខណៈ ៣២

[១] ក្នុងគម្ពីរអដ្ឋកថាទីឃនិកាយ នឹងអដ្ឋកថាមជ្ឈិមនិកាយ ពោលត្រូវគ្នាថា " ព្រះធាតុទាំងឡាយរបស់ព្រះបរមគ្រូកាលអណ្តែតត្រសែតចាកទីផ្សេងៗ មកសមោធានផ្តុំគ្នា នៅលើមហាពោធិបល្ល័ង្ក ហើយក៏កើតជាដុំមួយដូចជាដុំមាស បញ្ចេញ ឆព្វណ្ណ រង្សីផ្សាយចេញ ទៅពាសពេញទាំងហ្មឺនលោកធាតុ ហើយតេជោធាតុ បណ្តាលឆេះឡើងធ្វើ ឱ្យសុសសូន្យ បាត់ អស់ទៅ " មិនបានពោលថា ព្រះធាតុទាំងនោះ សមោធាននិម្មិតបានជា ព្រះពុទ្ធ រូប ១ ព្រះអង្គ ឡើយ ។

ប្រការ. អនុព្យញ្ជនៈ ៨០ នឹងកាំរស្មីមានប្រមាណមួយព្យាមជុំវិញ ទ្រង់គង់ដោយបល្ល័ង្កទៀបគល់មហាពោធិព្រឹក្សនោះឯង ដូចជាកាលព្រះបរមគ្រូទ្រង់គង់ព្រះជន្មនៅដូច្នោះដែរ ។ ក្នុងកាលនោះព្រះពុទ្ធនិម្មិតទ្រង់សំដែងឥទ្ធិបាដិហារ្យផ្សេងៗ ប្រាកដដូចជាក្នុងថ្ងៃដែលព្រះអង្គធ្វើយមកប្បាដិហារ្យ ទ្រង់បញ្ចេញពុទ្ធរស្មីទាំង ៦ពណ៌ ផ្សាយចេញទៅកាន់នភមណ្ឌលពេញមួយហ្មឺនលោកធាតុ. ឯពពួកសត្វជាមនុស្ស ពុំមានទៅកាន់ទីនោះទេមានតែពួកទេព្តា ។ គ្រានោះទេព្តាទាំងឡាយក្នុងមួយហ្មឺនចក្រវាឡបានប្រជុំគ្នាសំដែងសេចក្តីក្សីកក្សួលអាឡោះអាល័យថា ថ្ងៃនេះព្រះទសពលបរមគ្រូទ្រង់បរិនិព្វាន. ព្រះធាតុទាំងឡាយ នឹងសាបសូន្យទៅក្នុងថ្ងៃនេះ. នេះជាបច្ឆិមទស្សនៈរបស់យើងទាំងឡាយ ។ ឥឡូវនេះងងឹតអ័ព្ទអន្ធការនឹងកើតឡើង ចាប់តាំងពីពេលនេះតទៅដូច្នេះហើយក៏នាំគ្នាចុះចេញពីស្ថានវិមានរៀងៗខ្លួន សឹងដ៏មានបាត្តាកាន់នូវភ្នួងបុប្ផាកម្រង នឹងគ្រឿងសក្ការៈគ្រប់ប្រការ. ធ្វើនូវគារវភាពដ៏ធំក្រៃលែងជាងថ្ងៃ ដែលព្រះទសពល ទ្រង់រំលត់ខន្ធបរិនិព្វានជិតក្រុងកុសិនារានោះទៅទៀត ។ លំដាប់នោះ តេជោធាតុ ក៏តាំងឡើងអំពីធាតុសរីរៈ ឆេះជាភ្លើងមានអណ្តាតឡើង ញ៉ាំងធាតុសរីរៈនោះ ឱ្យដល់នូវភាពជារបស់សាបសូន្យអស់រលីងទៅ ពុំមានសេសសល់បន្តិចបន្តួចឡើយ ។ អណ្តាតភ្លើងដែលតាំងឡើងអំពីធាតុ សរីរៈនោះមានកំពស់ទៅក្នុងខាងលើ ដរាបដល់ ព្រហ្មលោកនាយ

ឯណោះ. ដរាបណា ព្រះធាតុសូម្បីប៉ុនគ្រាប់ស្ពៃមាននៅសល់. ដរាបនោះ អណ្តាតភ្លើង ក៏នៅមិនទាន់រលត់ទៅដែរ ។ អណ្តាតភ្លើងនឹងរលត់ដាច់ស្ងប់ស្ងាត់សូន្យទៅ នៅពេលដែលព្រះធាតុទាំងពួងសុសសាបសូន្យអស់រលីង ពុំមាននៅសេសសល់ តិចតួចឡើយ ។

**តទា សន្និបតិតទេវសង្ឃោ** គ្រានោះ ពួកទេវតាដែលមូលមកប្រជុំគ្នា បានប្រណម្យនមស្ការ ធ្វើសក្ការបូជាយ៉ាងមហោឡារិក អធិកអធម ថ្វាយចំពោះព្រះធាតុសរីរៈ ដោយវត្ថុធាតុផ្សេងៗ មានគ្រឿង ក្រអូប ផ្កាកំរង នឹងតូរ្យតន្ត្រីទិព្វជាដើម ដូចជាក្នុងថ្ងៃ ដែលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់រលត់ខន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុនោះឯង. រួចហើយពួកទេវតាទាំងនោះនាំគ្នាប្រទក្សិណបីជុំ លើកហត្ថាប្រណម្យថ្វាយបង្គំ ពោលថា "ភគវា បពិត្រព្រះមានជោគ! ខ្ញុំព្រះអង្គទាំងឡាយនេះ សូម ឱ្យបាន ទាន់ជួប នឹងព្រះពុទ្ធជាម្ចាស់ដែលនឹងបានត្រាស់ឡើងក្នុងអនាគតកាល កុំបីឃ្លៀងឃ្លាត " រួចស្រេចហើយ ក៏នាំគ្នាហោះទៅកាន់ស្ថានវិមានរៀងៗខ្លួនទៅ ។ កាលព្រះធាតុទាំងឡាយ សំដែងអានុភាពដ៏ធំយ៉ាងនេះ ហើយបរិនិព្វានអន្តរធានចាក លោកទៅក្នុង កាលណា. ក្នុងកាលនោះ ព្រះធាតុឈ្មោះថាអន្តរធានសាបសូន្យ ទៅពិត ប្រាកដ ។**ឥទំ ធាតុអន្តរធានំ នាម** នេះឯង ហៅថាធាតុអន្តរធាន ។

អន្តរធានទាំង ៥ យ៉ាង ដែលបានអធិប្បាយមកហើយនេះ មានបរិយត្តិអន្តរធានជាមូល. ត្បិតថាបើបរិយត្តិ អន្តរធានទៅសេចក្តីប្រតិបត្តិ ក៏អន្តរធានទៅដែរ. បើបរិយត្តិ ស្ថិតនៅ សេចក្តីប្រតិបត្តិក៏ស្ថិតនៅដែរ[១] ។ រឿងនេះមានកើតជាពាក្យជជែកប្រកែកគ្នាម្តងរួចទៅហើយ រវាងពួកបំសុកូលិកត្ថេរ នឹងពួកធម្មកថិកត្ថេរ ក្នុងសម័យក្រោយ ចណ្ឌាលតិស្សមហាភ័យកើតឡើង ។ សេចក្តីថាកាលចណ្ឌាលតិស្សមហាភ័យកើតឡើងក្នុងទ្វីបនេះ សម្តេចអមរិន្ទ្រាធិរាជទ្រង់និម្មិតក្បូនធំ ១ ហើយទ្រង់ត្រាស់ប្រគេនដំណឹងដល់ភិក្ខុទាំងឡាយថា "បន្តិចទៀតមហាភ័យ នឹងកើតឡើង ត្បិតភ្លៀងពុំបង្អុរធ្លាក់ចុះមកដោយស្រួល. ភិក្ខុទាំងឡាយ នឹងលំបាកដោយបច្ច័យបិណ្ឌបាតមិនអាចនឹងទ្រទ្រង់បរិយត្តិឱ្យគង់វង្សបាន ដូច្នេះ គួរតែលោកម្ចាស់ទាំងឡាយ និមន្តទៅគង់នៅត្រើយខាងនាយឯណោះសិន ដើម្បីរក្សាជីវិតកុំឱ្យវិនាសទៅក្នុងមហាភ័យនេះ. បពិត្រលោកម្ចាស់ដ៏ចំរើនទាំងឡាយ ! សូមលោកម្ចាស់ទាំងឡាយ និមន្ត

---

[១] ក្នុងភិក្ខុខន្ធកវណ្ណនាលោកពោលថា " បរិយត្តិធម៌ នឹងស្ថិតនៅដល់ ៥ ពាន់ឆ្នាំ កាលបើបរិយត្តិមិនមាន បដិវេធៈ ( ការចាក់ធ្លុះនូវមគ្គនឹងផល ) ក៏មិនមានដែរ. បើបរិយត្តិមាន. បដិវេធ ឈ្មោះថាមិនមានក៏ទេ ។ ឯលិង្គ : គឺភេទអ្នកបួសបើទុកជាបរិយត្តិអន្តរធានសាបសូន្យទៅក៏នៅអាចប្រព្រឹត្តទៅអស់កាលដ៏យូរបាន " ។

ឡើងគង់លើក្បូនធំនេះមក បើក្បូននេះចង្អៀតមិនចុះគ្រប់អង្គទេ សូមលោកម្ចាស់អង្គខ្លះតោងកំណាត់ឈើហែលឆ្លងទៅ. កាលបើដូច្នេះ ភ័យនឹងមិនកើតមានដល់លោកម្ចាស់គ្រប់អង្គឡើយ" ។ ក្នុងកាលនោះមានភិក្ខុ ៦០ រូបបាននិមន្តទៅដល់ឆ្នេរសមុទ្រ ហើយក៏ធ្វើសេចក្តីប្តេជ្ញាគ្នាថា "ដំណើរទៅក្នុងត្រើយខាងនាយនោះ មិនត្រូវមានដល់ពួកយើងទេ យើងទាំងឡាយនឹងនៅទ្រទ្រង់ថែរក្សាព្រះត្រៃបិដក នាត្រើយខាងអាយនេះចុះ" ដូច្នេះហើយក៏ព្រមព្រៀងគ្នាត្រឡប់អំពីទីនោះមកវិញ មានមុខឆ្ពោះទៅកាន់ទក្ខិណាមលយជនបទ នៅអាស្រ័យក្នុងទីនោះទៅ ចិញ្ចឹមជីវិតតែដោយមើមដំឡូង នឹងស្លឹកឈើផ្សេងៗ ប៉ុណ្ណោះ ។ កាលបើរាងកាយ មានកំលាំងប្រព្រឹត្តទៅគ្រប់គ្រាន់ក៏នាំគ្នាអង្គុយស្វាធ្យាយបរិយត្តិ. បើរាងកាយមិនមានកំលាំងទេ ក៏នាំគ្នាកៀវប្រមូលដីខ្សាច់ឱ្យកើតជាពំនូកធំឡើងហើយអង្គុយព័ទ្ធជុំវិញ យកខ្នងទល់នឹងពំនូកខ្សាច់ធ្វើសិសៈឱ្យរួមចូលប៉ះគ្នា ពិចារណាបរិយត្តិ ។ ភិក្ខុទាំង ៦០រូបនោះខំប្រឹងព្យាយាមយកចិត្តទុកដាក់ ក្នុងការទ្រទ្រង់ថែរក្សាព្រះត្រៃបិដកព្រមទាំងអដ្ឋកថាឱ្យគង់វង្សនៅបរិបូរតាមទំនងនេះអស់វារកាល ១២ ឆ្នាំ ។ ចំណែកខាងភិក្ខុ ៧០០ រូបផ្សេងទៀត ដែលបានគេចឆ្លងទៅនៅអាស្រ័យនាត្រើយខាងនាយនោះ ក៏ខំប្រឹងរក្សាព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ឱ្យគង់វង្សនៅបរិបូរដូចគ្នាដែរ សូម្បីតែអក្ខរៈ ១ តួ ឬព្យញ្ជនៈ ១ តួក៏មិនឱ្យវិនាស

ទៅឡើយ. កាលភ័យស្ងប់រម្ងាប់ហើយ ភិក្ខុទាំង ៧០០ រូបនោះក៏ត្រលប់មកកាន់ទ្វីបនោះវិញ ចូលទៅនៅក្នុងមណ្ឌលារាម ក្នុងកល្លគាមជនបទ ។ ប៉ែកខាងភិក្ខុ ៦០ រូបដែលក្រាញនៅក្នុងទ្វីបឯណោះ កាលបានជ្រាបពត៌មានថាព្រះថេរៈទាំងឡាយ ត្រឡប់មកដល់វិញហើយ ក៏នាំគ្នាធ្វើដំណើរកាត់ទៅជួប. លុះទៅដល់ បានសន្ទនាសំណេះសំណាលប្រាស្រ័យរាក់ទាក់ជាកិច្ចបដិសណ្ឋារៈ តាមទំនៀមរួចហើយក៏សុំផ្ទៀងជំរះព្រះត្រៃបិដកជាមួយនឹងព្រះថេរៈទាំងឡាយនោះ ដល់ផ្ទៀងរួចស្រេចហើយ ពុំឃើញមានវិបត្តិភ្លាំងភ្លាត់បន្តិចបន្តួចសោះ សូម្បីតែអក្ខរៈ ១តួ ក៏មិនបាត់ ឬមិនឃ្លៀងឃ្លាតពីគ្នាផងដែរ ។ ក្នុងវេលានោះ ភិក្ខុជាថេរៈទាំងឡាយ បានញុំាងកថាឱ្យកើតឡើងក្នុងទីនោះថាបរិយត្តិ ជាឫសគល់នៃសាសនា ឬ? ឬក៏បដិបត្តិ ? កាលត្រូវសួរដូច្នេះហើយពួកបំសុកូលិកត្ថេរឆ្លើយឡើងថា បដិបត្តិជាឫសគល់នៃសាសនា ។ឯពួកភិក្ខុជាធម្មថិកឆ្លើយថាបរិយត្តិ ។

ខណៈនោះ ភិក្ខុជាថេរៈទាំងឡាយ ប្រកាសឡើងថា យើងទាំងឡាយមិនព្រមយកពាក្យត្រឹមតែប៉ុណ្ណោះ របស់អ្នកទាំងពីរខាងមកជាប្រមាណទេត្រូវឱ្យអ្នកទាំងពីរខាង លើកយកសូត្រជាភាសិតរបស់ព្រះជិនស្រី មកពោលអាងផងទើបបាន ។ លំដាប់នោះ ពួកបំសុកូលិកត្ថេរពោលថា ការលើកយកសូត្រមកពោលអាងក៏មិនជាការធ្ងន់អ្វីទើបលើកយកសូត្រពីរកន្លែងមកពោល

អាងថា **ឥមេ ច សុភទ្ទ ភិក្ខូ សម្មាបដិបត្តី វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ អស្ស** "ម្នាលសុភទ្ទ ! ប្រសិនបើ ភិក្ខុទាំងឡាយនេះ មានការប្រតិបត្តិត្រឹមត្រូវជាប្រក្រតី លោក (នេះ) ក៏មិនគប្បីសូន្យចាកព្រះអរហន្តទាំងឡាយឡើយ" ។ **បដិបត្តិមូលកំ មហារាជ សត្ថុសាសនំ បដិបត្តិយំ ធរន្តេ តិដ្ឋតិ** "បពិត្រមហារាជ ! សាសនារបស់ព្រះបរមគ្រូ មានសេចក្តី ប្រតិបត្តិជាឫសគល់ ស្ថិតនៅក្នុងបុគ្គលអ្នកទ្រទ្រង់សេចក្តីប្រតិបត្តិ" ។ ដើម្បី នឹងតំកល់វាទៈរបស់ខ្លួនឱ្យជាប់មាំមួនឡើង ទើបពួកភិក្ខុជាធម្មកថិក ក៏នាំយក សូត្រដូចខាងក្រោមនេះ មកពោលអាងថា

**យាវ តិដ្ឋន្តិ សុត្តន្តា វិនយោ យាវ ទិប្បតិ**
**តាវ ទក្ខន្តិ អាលោកំ សុរិយេ អព្ភុដ្ឋិត យថា ។**
**សុត្តន្តេសុ អសន្តេសុ បម្មុដ្ឋេ វិនយម្ហិ ច**
**តមោ ភវិស្សតិ លោកស្ស សុរិយេ អត្ថង្គតេ យថា ។**
**សុត្តន្តេ រក្ខិតេ សន្តេ បដិបត្តិ ហោតិ រក្ខិតា**
**បដិបត្តិយំ ឋិតោ ធីរោ យោគក្ខេមា ន ធំសតីតិ ។**

"ព្រះសូត្រទាំងឡាយ ស្ថិតនៅដរាបណា, ព្រះវិន័យ នៅរុងរឿងដរាបណា, (សត្វលោក) ក៏នៅឃើញពន្លឺដរាបនោះ ដូចជាព្រះអាទិត្យដែលរះឡើងចែង ច្បាស់ដូច្នោះឯង ។ កាលបើព្រះសូត្រទាំងឡាយមិនមាន, ទាំងព្រះវិន័យ ក៏ភិក្ខុភ្លេចអស់ទៅហើយផង , ងងឹតអ័ព្ទអន្ធការ នឹងកើតមានដល់សត្វ

លោក ដូចជាព្រះអាទិត្យ ដែលអស្តង្គតបាត់ពន្លឺរស្មី ទៅដូច្នោះឯង ។ កាលបើភិក្ខុនៅរក្សាព្រះសូត្រនៅឡើយ, ការប្រតិបត្តិ ក៏ឈ្មោះថាជាគុណជាតិគឺភិក្ខុនៅរក្សាដែរ, ធីរជនអ្នកស្ថិតនៅក្នុងការ ប្រតិបត្តិ រមែងមិនឃ្លាតចាកធម៌ជាដែនក្សេមចាកយោគៈឡើយ ” ។

កាលពួកភិក្ខុជាធម្មកថិក នាំយកសូត្រនេះមកសំដែងអាងហើយ ពួកបំសុកូលិកត្ថេរ ក៏នៅស្ងៀមទៅ ។ ដូច្នេះ ពាក្យរបស់ធម្មកថិកត្ថេរទាំងឡាយក៏ឈ្មោះថាមានប្រៀបលើពាក្យរបស់ពួកបំសុកូលិកត្ថេរ ។ សេចក្ដីនេះព្រះអដ្ឋកថាចារ្យ លោកអធិប្បាយឧបមាប្រៀបធៀបបំភ្លឺថា “ហ្វូងគោដែលមានសុទ្ធតែគោបាទាំងរយទាំងពាន់ កាលបើមិនមានមេគោ ជាសត្វរក្សាដំណបវេណី នៅក្នុងហ្វូងនោះផងទេ, វង្ស បវេណីឬពូជនោះក៏មុខជានឹងដាច់សូន្យទៅ យ៉ាងណាមិញ, ក្នុងសាសនានេះក៏ដូច្នេះដែរ, បើទុកជាមានភិក្ខុច្រើនរូប ដល់រយពាន់ សុទ្ធតែជាអ្នកប្រារព្ធនូវវិបស្សនាកម្មដ្ឋាន ធុតង្គរុក្ខមូលនៅអាស្រ័យក្នុងព្រៃក៏ដោយតែបើពុំមានភិក្ខុអ្នកទ្រទ្រង់បរិយត្តិទេ ឬកបរិយត្តិអន្តរធានទៅ ដោយហេតុណាមួយហើយ ការចាក់ធ្លុះនូវអរិយមគ្គ-ផលក៏ពុំមានដែរព្រោះពុំមានបរិយត្តិ ជាច្បាប់សំរាប់ពន្យល់បំភ្លឺផ្លូវប្រតិបត្តិឱ្យត្រឹមត្រង់ទៅបាន ។ ន័យមួយទៀតថា អក្ខរៈទាំងឡាយ ដែលគេធ្លាក់នៅលើផ្ទាំងថ្មដើម្បីប្រយោជន៍ជាគ្រឿងសំគាល់ឱ្យដឹងនូវទីនៃឆ្នាំងកំណប់ទ្រព្យដែលគេកប់ទុក, ដរាបណាអក្ខរៈទាំងឡាយនោះ នៅមិនទាន់រលាយរលប់បាត់បង់ទៅទេ, ដរាបនោះ ឆ្នាំងកំណប់ទ្រព្យនោះឈ្មោះថាវិនាសបាត់បង់ទៅហើយ ក៏ពុំមែន

ដែរ យ៉ាងណាមិញ. ឯសាសនានេះ ក៏យ៉ាងនោះ.បើបរិយត្តិ នៅមានភិក្ខុទ្រទ្រង់នៅឡើយ ឬក៏មិនទាន់អន្តរធានទៅទេ. សាសនាក៏មិនទាន់អន្តរធានសាបសូន្យទៅដែរ. ព្រោះអាស្រ័យបរិយត្តិជាប្រមាណ គឺបរិយត្តិ ជាឫសគល់របស់សាសនា ។

កាលព្រះធាតុទាំងឡាយ របស់ព្រះបរមគ្រូនិព្វានអន្តរធានបាត់បង់ចាកលោកទៅហើយ ទើបបើកឱកាសឱ្យដល់ព្រះតថាគតអរហន្ត សម្មាសម្ពុទ្ធអង្គដទៃក្រោយ ។

ព្រោះហេតុដូចម្តេច បានជាព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទាំងឡាយ ២ ព្រះអង្គ មិនត្រាស់ឡើងក្នុងលោកធាតុ ១ ដំណាលគ្នា ? ព្រោះហេតុមិនជាទីអស្ចារ្យ ត្បិតព្រះពុទ្ធទាំងឡាយ ជាមនុស្សអស្ចារ្យ ។ សេចក្តីនេះសមដូចជាព្រះពុទ្ធដីការដែល ព្រះបរមគ្រូទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា **ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អច្ឆរិយមនុស្សោ, កតមោ, ឯកបុគ្គលោ ? តថា គតោ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ** "ម្នាលភិក្ខុទាំងឡាយ ! បុគ្គលម្នាក់ កាលដែលកើតឡើងក្នុងលោក ក៏កើតឡើងជាមនុស្សអស្ចារ្យ បុគ្គលម្នាក់ (នោះ) គឺអ្នកណា ? ម្នាលភិក្ខុទាំងឡាយ ! គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ " ។ ប្រសិនបើព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ២ អង្គ ៤ អង្គ ៨ អង្គ ឬ ១៦ អង្គត្រាស់ឡើងដំណាលគ្នា ក្នុងពេល ១ តែម្តង នោះក្នុងលោកទាំងមូល ក៏មិនជាទីស្ងើចអស្ចារ្យអ្វីឡើយ ប្រៀបដូចក្នុងវត្ត ១ បើមានចេតិយ ២ រមែងមិនកើត

មានគ្រឿងលាភសក្ការៈដ៏ឧឡារិកប៉ុន្មាន, ទាំងភិក្ខុជាសាវ័ក ទាំងឡាយ ក៏មិនជាទីអស្ចារ្យ ព្រោះមានសាស្ដាច្រើនអង្គនោះដែរ ។ ម្យ៉ាងទៀត ព្រោះមិនផ្សេងគ្នាដោយធម្មទេសនាផង, ត្បិតថា ធម៌ដែលព្រះពុទ្ធច្រើនព្រះអង្គនោះទ្រង់សំដែង ក៏មិនមានដំណើរសេចក្ដីនឹងអត្ថរសប្លែកគ្នា. បើព្រះពុទ្ធ ១ អង្គទ្រង់សំដែងធម៌ណាមួយ មានសតិបដ្ឋានធម៌ជាដើម ធម៌នោះ ព្រះពុទ្ធអង្គដទៃ ក៏ត្រូវតែសំដែងដូច្នោះដែរ នឹងបំបែរឱ្យប្លែកគ្នាពុំបាន. ឯផលទីបំផុតនៃការប្រតិបត្តិធម៌ដែលកើតឡើងដល់ពួកពុទ្ធបរិស័ទនោះ គឺបានសំរេចសម្បត្តិព្រះនិព្វានដូចគ្នា. ម្ល៉ោះហើយធម្មទេសនានោះ ក៏មិនមែនជាទីស្ងើចអស្ចារ្យអ្វីប៉ុន្មានដល់ពួកបរិស័ទ ។ បើព្រះពុទ្ធត្រាស់ឡើងតែ ១ អង្គ ទ្រង់សំដែងធម៌ប្រោសសត្វ , ធម្មទេសនារបស់ព្រះអង្គនោះ ទើបជាទីស្ងើចអស្ចារ្យដល់សន្ដានពួកបរិស័ទ ។ ម្យ៉ាងទៀត នឹងនាំឱ្យមានការជជែកប្រកែកប្រណាំងយកប្រៀបលើគ្នា រវាងក្រុមពុទ្ធបរិស័ទ នឹងក្រុមពុទ្ធបរិស័ទទៀតផង. ត្បិតថាព្រះពុទ្ធត្រាស់ ឡើងច្រើនព្រះអង្គ ក៏មិនខុសគ្នាអំពីសិស្ស ច្រើនរូប អាចារ្យច្រើនរូបដូច្នោះដែរ. ពួកបរិស័ទនឹងជជែកប្រកែកប្រណាំងគ្នាថា "ព្រះពុទ្ធរបស់យើងទាំងឡាយគួរជាទីជ្រះថ្លា ព្រះពុទ្ធ របស់យើងទាំងឡាយ ទ្រង់មានព្រះសូរសៀង ពិរោះក្រាំងក្រអៅ, ទ្រង់មានលាភ, ទ្រង់មានបុណ្យច្រើន " ។ ព្រោះហេតុ នោះព្រះពុទ្ធទាំងឡាយច្រើនព្រះអង្គ នាំឱ្យមានដំណើរ ប្រព្រឹត្តទៅបែប នេះ បានជាមិនត្រាស់ឡើងដំណាលគ្នាក្នុងពេល ១ ។

ដំណើរនេះ សមដូចជាសេចក្ដីអធិប្បាយ ដែលព្រះនាគសេនត្ថេរ សំដែង

ថ្វាយ ព្រះបាទមិលិន្ទរាជទ្រង់ព្រះសណ្ដាប់ដូចតទៅនេះ :

ព្រះបាទមិលិន្ទរាជទ្រង់ត្រាស់សួរព្រះនាគសេនត្ថេរថា បពិត្រព្រះនាគសេនដ៏ចំរើន ! ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ! ព្រះអរហន្តសម្មា សម្ពុទ្ធទាំងឡាយ ២ ព្រះអង្គ ត្រាស់ឡើងក្នុងលោកធាតុ ១ ដំណាលគ្នាមិនមែនជាឋានៈ គឺមិនមានហេតុ ជាទីតាំងនៃផលឡើយបពិត្រ ព្រះនាគសេនដ៏ចំរើន! សូម្បីព្រះតថាគតទាំងឡាយគ្រប់ព្រះអង្គ កាលនឹង ទ្រង់សំដែង (ចង្អុលបង្ហាញ) ទ្រង់តែងសំដែង (ចង្អុលបង្ហាញ) នូវពោធិបក្ខិយធម៌ ៣៧ ប្រការ, កាលនឹង ទ្រង់ពោលទ្រង់តែងពោលនូវ ចតុរារិយសច្ចទាំងឡាយ, កាលនឹងទ្រង់ឱ្យសិក្សា ទ្រង់តែងឱ្យសិក្សាក្នុងត្រៃ សិក្ខាទាំងឡាយ, កាលនឹងទ្រង់ប្រៀនប្រដៅទ្រង់តែងប្រៀនប្រដៅនូវ អប្បមាទប្បដិបទា, បពិត្រព្រះនាគសេនដ៏ចំរើន! ប្រសិនបើ ព្រះតថាគតទាំង ឡាយគ្រប់ព្រះអង្គទ្រង់មានឧទ្ទេសតែមួយបែប, មានកថាតែមួយបែប, មានសិក្ខាបទតែមួយបែប, មានអនុសាសនៈ (ពាក្យប្រៀនប្រដៅ) តែមួយបែបទេ ចុះហេតុដូចម្ដេចក៏បានជាព្រះតថាគតទាំងឡាយ ២ ព្រះអង្គ មិនត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នា ? មួយទៀត, លោកនេះ មានពន្លឺភ្លឺស្វាងកើតឡើងដោយពុទ្ធុប្បាទមួយម្លេះទៅហើយ ចំណង់បើ ព្រះពុទ្ធអង្គគំរប់ពីរ ត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នាទៀត លោកនេះក៏ រឹងរឹតតែមានពន្លឺភ្លឺស្វាងរុងរឿងក្រៃលែងជាភិយ្យោភាពទៅទៀត ដោយពន្លឺនៃព្រះពុទ្ធទាំងពីរអង្គនោះរួមគ្នា. ប្រការមួយទៀត ព្រះតថាគតទាំងឡាយ ២ ព្រះអង្គនោះ កាលនឹងទ្រង់ប្រទានឱវាទ

ក៏ទ្រង់ប្រទានដើម្បីឱ្យបានសុខចំរើន, កាលនឹងទ្រង់ប្រៀនប្រដៅ ក៏ទ្រង់ប្រៀនប្រដៅដើម្បីឱ្យបានសុខចំរើន ដូចគ្នាទេ, បពិត្រព្រះនាគសេនដ៏ចំរើន ! ចុះដំណើរហេតុនេះ យ៉ាងណាហ្ន៎ ? សូមលោកម្ចាស់ ពន្យល់បំភ្លឺឱ្យត្រាតែខ្ញុំអស់សេចក្តីសង្ស័យងឿងឆ្ងល់ផង ។

ព្រះនាគសេនត្ថេរថ្វាយព្រះពរតបថា "បពិត្រមហារាជ! លោកធាតុ ១ ហ្មឺននេះ មានប្រក្រតីទ្រទ្រង់បានតែព្រះពុទ្ធ ១ អង្គ ទ្រទ្រង់នូវគុណព្រះតថាគតបានត្រឹមតែ ១ អង្គប៉ុណ្ណោះ, ប្រសិនបើព្រះពុទ្ធអង្គទី២ទ្រង់ត្រាស់ឡើងថែមទៀត លោកធាតុ ១ ហ្មឺននេះនឹងទ្រទ្រង់ពុំបាន ទៅជាក៏ក្រើកញាប់ញ័ររញ្ជួយ រេកខ្ទេចរាត់រាយខ្ចាត់ខ្ចាយនឹងតាំងនៅតាមធម្មតាមិនបាន, បពិត្រមហារាជ ! ដំណើរនេះ មានឧបមាដូចជាទូកតូចដែលមានចំណុះតែម្នាក់ គឺទ្រនូវទំងន់បុរសបានតែម្នាក់ កាលបើបុរសម្នាក់ឡើងជិះហើយ ទូកតូចនោះក៏អាចរត់ទៅលើខ្នងទឹកបានដោយស្រួល បន្ទាប់មកមានបុរសម្នាក់ទៀតមកដល់បុរសទីពីរនេះមានរូបរាងដូចគ្នា ឬស្មើគ្នានឹងបុរសទីមួយ ដោយអាយុដោយពណ៌ សម្បុរដោយវ័យ ដោយកំពស់ ដោយស្គមនឹងធាត់ ដោយអវយវៈតូច ធំទាំងអស់ ហើយក៏ឡើងជិះទូកនោះទៀត បពិត្រមហារាជ! តើទូកនោះអាចទ្រនូវទំងន់នៃបុរសទាំងពីរនាក់នោះបានដែរឬទេ ?

ព្រះបាទមិលិន្ទ- មិនបានទេ លោកម្ចាស់ ! ទូកនោះ មុខជារញ្ជួយញាប់ញ័រឃ្លេងឃ្លោង លិចចុះទៅក្នុងទឹកមិនខាន ។

ព្រះនាគសេនត្ថេរ- បពិត្រមហារាជ! ដំណើរហេតុនោះយ៉ាងហ្នឹងឯង,

លោកធាតុ ១ ហ្មឺននេះ មានប្រក្រតីទ្រទ្រង់បាននូវព្រះពុទ្ធតែ ១អង្គ ទ្រទ្រង់នូវគុណព្រះតថាគតបានត្រឹមតែ ១ អង្គប៉ុណ្ណោះប្រសិនបើព្រះពុទ្ធអង្គគំរប់ពីរ ទ្រង់ត្រាស់ឡើងថែមទៀត លោកធាតុ ១ ហ្មឺននេះ នឹងទ្រទ្រង់មិនបាន ទៅជាកក្រើកញាប់ញ័ររញ្ជួយបែកខ្ញែករាត់រាយខ្ចាត់ខ្ចាយ តាំងនៅតាមធម្មតាមិនបាន ។ បពិត្រមហារាជ ! ន័យមួយទៀត ដូចជាបុរសអ្នកបរិភោគភោជនដរាបដល់ឆ្អែត, បុរសនោះបានញ៉ាំងផ្ទៃដែលត្រូវសេចក្ដីឃ្លានគ្របសង្កត់ឱ្យពេញដល់ក ឈ្មោះថាឆ្អែតស្កប់ស្កល់ហើយមានដងខ្លួនត្រង់ ឱនឬបន្ទន់ចុះមិនបាន ហើយបុរសនោះត្រូវបរិភោគភោជនមានប្រមាណប៉ុណ្ណោះម្ដងទៀត. បពិត្រមហារាជ! តើបុរសនោះ នឹងគប្បីជាអ្នកបានដល់នូវសេចក្ដីសុខដែរឬ ទេ?

ព្រះបាទមិលិន្ទ- បពិត្រលោកម្ចាស់ដ៏ចំរើន ! បុរសនោះមិនបានដល់នូវសេចក្ដីសុខទេ. តែបរិភោគដូច្នោះម្ដងទៀត មុខជានឹងដល់នូវសេចក្ដីស្លាប់មិនខាន ។

ព្រះនាគសេនត្ថេរ- បពិត្រមហារាជ! ដំណើរហេតុនោះ យ៉ាងហ្នឹងឯង. លោកធាតុ ១ហ្មឺននេះ មានប្រក្រតីទ្រទ្រង់បាននូវព្រះពុទ្ធតែត្រឹម ១ អង្គ ។ល។ តាំងនៅតាមធម្មតាមិនបាន ។

ព្រះបាទមិលិន្ទ- បពិត្រព្រះនាគសេនដ៏ចំរើន ! មហាប្រឹថពីនេះកក្រើកញាប់ញ័រ ដោយបន្ទុកនៃធម៌ដ៏ធ្ងន់ហួសប្រមាណយ៉ាងនេះឬ ?

ព្រះនាគសេនត្ថេរ- បពិត្រមហារាជ ! សូមមហារាជទ្រង់ព្រះសណ្ដាប់

នូវសេចក្តីឧបមា ដែលអាត្មាភាពនឹងសំដែងថ្វាយក្នុងកាលឥឡូវនេះ ។ បពិត្រមហារាជ ! សេចក្តីនេះ ឧបមាដូចជារទេះពីរ ដែលសុទ្ធតែផ្ទុកទៅដោយរតនវត្ថុមានទំងន់ដូចគ្នាតាមចំណុះ ហើយជនទាំងឡាយដកយករតនវត្ថុទាំងអស់អំពីរទេះមួយ ទៅចាក់រោយរាយបំពេញក្នុងរទេះមួយដែលផ្ទុកដោយទំងន់ដូចគ្នាតាមចំណុះទៅហើយនោះ ថែមលើរតនវត្ថុមុនមួយជាន់ទៅទៀត. បពិត្រមហារាជ! តើរទេះនោះ អាចទ្រទ្រង់នូវទំងន់នៃរតនវត្ថុរបស់រទេះពីរបានដែរឬទេ ?

ព្រះបាទមិលិន្ទ- មិនបានទេ លោកម្ចាស់! រទេះនោះ មុខតែរញ្ជួយដុំ, បាក់កាំ, ធ្លាក់ខ្នងកង់, បាក់ភ្លៅមិនខាន ។

ព្រះនាគសេនត្ថេរ- បពិត្រមហារាជ ! រទេះនោះបាក់បែកទៅដោយបន្ទុកនៃរតនវត្ថុដ៏ធ្ងន់ហួសប្រមាណដូច្នោះឬ ?

ព្រះបាទមិលិន្ទ- ករុណា លោកម្ចាស់ !

ព្រះនាគសេនត្ថេរ- បពិត្រមហារាជ ! មហាប្រឹថពីនេះ ក៏តែងកក្រើកញាប់ញ័រដោយបន្ទុកនៃធមិដ៏ធ្ងន់ហួសប្រមាណដូច្នោះឯង ។ម្យ៉ាងទៀតដំណើរហេតុនេះ ប្រជុំចុះមកជាគ្រឿងសំដែងឱ្យឃើញជាក់ច្បាស់ នូវកំលាំងនឹងអានុភាពរបស់ព្រះពុទ្ធទាំងឡាយ. សូមមហាបពិត្រទ្រង់ព្រះសណ្តាប់នូវហេតុដទៃទៀត. ក្នុងដំណើរដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ២ ព្រះអង្គមិនត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នា ។ បពិត្រមហារាជ ! ប្រសិនបើព្រះសម្មាសម្ពុទ្ធទាំងឡាយ ២ ព្រះអង្គត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នា

ការវិវាទរវាងពួកបរិស័ទនឹងពួកបរិស័ទ មុខតែនឹងកើតឡើង ហើយនឹងបែកបាក់គ្នាជាបក្សពួកដោយកិរិយាប្រកាន់មាំថា "ព្រះពុទ្ធនោះ របស់អ្នក, ព្រះពុទ្ធនេះរបស់យើង" ប្រៀបដូចពួកបរិស័ទរបស់មហាមាត្យពីររូប កើតវិវាទនឹងគ្នាហើយបែកបាក់គ្នាជាបក្សពួកពីរចំណែក ដោយសេចក្តី ប្រកាន់ថា "អាមាត្យនោះរបស់អ្នក, អាមាត្យនេះរបស់យើង " ដូច្នេះយ៉ាងណាមិញ, បពិត្រមហារាជ ! ដំណើរហេតុនោះ ក៏យ៉ាងហ្នឹងឯង, ប្រសិនបើ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ២ព្រះអង្គ ត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នា ការវិវាទគ្នានឹងគប្បី កើតឡើងដល់ពួកបរិស័ទ ហើយនឹង បែកបាក់គ្នាជា បក្សពួកពីរចំណែកដោយកិរិយាប្រកាន់មាំថា "ព្រះពុទ្ធនោះរបស់អ្នក, ព្រះពុទ្ធនេះរបស់យើង" ។ នេះជាហេតុទីមួយ ក្នុងដំណើរដែល ព្រះសម្មាសម្ពុទ្ធទាំងឡាយពីរព្រះអង្គមិនត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នា ។ សូមមហាបពិត្រទ្រង់ព្រះសណ្តាប់នូវហេតុដ៏ក្រៃលែងជាងនេះទៅទៀត ក្នុង ដំណើរដែលព្រះសម្មាសម្ពុទ្ធទាំងឡាយពីរព្រះអង្គមិនត្រាស់ឡើងក្នុងខណៈ មួយដំណាលគ្នា ។ បពិត្រមហារាជ ! ប្រសិនបើ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ២ ព្រះអង្គត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នា ឯពាក្យថា "ព្រះពុទ្ធព្រះអង្គជាអគ្គបុគ្គល" ក្តី "ព្រះពុទ្ធ ព្រះអង្គជា បុគ្គលច្បង" ក្តី "ព្រះពុទ្ធ ព្រះអង្គជាបុគ្គលប្រសើរផុត" ក្តី "ព្រះពុទ្ធព្រះអង្គជា បុគ្គលថ្លៃថ្លា" ក្តី "ព្រះពុទ្ធ ព្រះអង្គជាបុគ្គលឧត្តម" ក្តី "ព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើក្តី "ព្រះពុទ្ធព្រះអង្គស្មើ

ដោយព្រះពុទ្ធមិនមានបុគ្គលស្មើ" ក្តី " ព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលប្រៀបស្មើ" ក្តី ព្រះពុទ្ធ ព្រះអង្គមិនមានចំណែកប្រៀប" ក្តី "ព្រះពុទ្ធ ព្រះអង្គមិនមានប្រៀបផ្ទឹម" ក្តី ទាំងអស់នេះ នឹងគប្បីត្រលប់ទៅជាពាក្យផ្ទុយខុសទៅវិញ ។ បពិត្រមហារាជ! សូមព្រះអង្គទ្រង់ជ្រាប នូវហេតុក្នុងដំណើរដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ២ ព្រះអង្គ មិនត្រាស់ឡើងក្នុងខណៈមួយដំណាលគ្នា តាមន័យ នេះចុះ ។ បពិត្រមហារាជ ! ន័យមួយវិញទៀត ការត្រាស់ដឹងឡើងក្នុងលោក នៃព្រះពុទ្ធតែ ១ អង្គគត់ក្នុងខណៈមួយនេះ គឺជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ។ ព្រោះហេតុអ្វី ? ព្រោះថាគុណនៃសព្វញ្ញុពុទ្ធទាំងឡាយជាសភាវៈធំលើសជាងហេតុ. សេចក្តីនេះ សូម្បីវត្ថុផ្សេងៗ ក៏តែងតែប្រព្រឹត្តទៅដូច្នេះដែរ គឺវត្ថុណាដែលធំប្រសើរថ្លៃថ្លាខ្ពង់ខ្ពស់ ឆ្នើមជាងគេ វត្ថុនោះ តែងមានត្រឹមតែមួយគត់ មិនដែលមានដល់ពីរឡើយ ។ បពិត្រមហារាជ !ប្រឹថពីធំ ប្រឹថពីនេះ មានតែ ១ គត់, សាគរធំ សាគរនោះ ក៏មានតែ ១គត់, ស្តេចភ្នំឈ្មោះសិនេរុ ធំប្រសើរវិសេសលើសភ្នំដទៃៗទាំងអស់ ស្តេចភ្នំនោះក៏មានតែ ១គត់, អាកាសធំ អាកាសនោះក៏មានតែ ១ គត់, ព្រះឥន្ទ្រធំជាងទេវតាទាំងឡាយ ព្រះឥន្ទ្រនោះ ក៏មានតែមួយអង្គគត់, ព្រហ្មជាធំនោះក៏មានតែ ១គត់, ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាអគ្គបុគ្គលប្រសើរចម្បងជាងទេពតា នឹងមនុស្ស ទាំងឡាយក្នុងត្រៃលោក ព្រះតថាអរហន្តសម្មាសម្ពុទ្ធនោះ ក៏មានតែត្រឹម ១ អង្គគត់ ព្រះអង្គទ្រង់ឧប្បត្តិឡើងក្នុងលោកកាលណា ក្នុងកាលនោះ

ឱកាសមិនបើកឱ្យដល់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធអង្គដទៃ ៗ ឡើយ. ព្រោះហេតុនោះ នៅក្នុងលោកតែងមានព្រះតថាគតអរហន្តសម្មាសម្ពុទ្ធតែត្រឹម ១អង្គគត់ ត្រាស់ឡើងក្នុងខណៈមួយជាធម្មតា ។

ព្រះបាទមិលិន្ទទ្រង់មានព្រះបន្ទូលតបថា បពិត្រព្រះនាគសេនដ៏ចំរើន ! លោកម្ចាស់ឆ្លៀវឆ្លាតប៉ិនប្រសប់វាងវៃណាស់ ចេះលើយករឿងរ៉ាវផ្សេងៗជាឧទាហរណ៍ មកឧបមាប្រៀបធៀបប្រកបក្នុងការដោះស្រាយអាថិប្រស្នារដ៏ជ្រៅយ៉ាងនេះ ឱ្យទៅជារាក់ងាយស្តាប់ត្រាតែខ្ញុំចូលចិត្តអស់សេចក្តីងឿងឆ្ងល់សង្ស័យទៅបាន កុំចាំបាច់និយាយថ្វីឡើយ ដល់បុគ្គលជាមហា បុថុជ្ជន អម្បាលយ៉ាងខ្ញុំនេះ សូម្បីតែជនអ្នកមិនសូវចេះដឹង ក៏គង់តែស្តាប់ចូលចិត្ត យល់បានដោយងាយដែរ ។

ចប់ **អន្តរធានកថា** ដោយសង្ខេប

ហេតុដែលនាំឱ្យចំរើន នឹងហេតុដែលនាំឱ្យសាបសូន្យដល់ពុទ្ធសាសនា ដូចមានសេក្តីអធិប្បាយតទៅនេះ :

## ធម្មជាតិ ៣ យ៉ាង

ជាពន្លឺសំរាប់បំភ្លឺសត្វលោកឱ្យភ្លឺជាក់ច្បាស់ក្នុងលោក អាស្រ័យដោយពុំមានគ្រឿងសៅហ្មងអ្វីមកបៀតបៀន ឯធម្មជាតិ ៣ យ៉ាងនោះគឺ :

១. **សុរិយមណ្ឌល** មណ្ឌលព្រះអាទិត្យ ។

**២. ចន្ទមណ្ឌលំ** មណ្ឌលព្រះចន្ទ ។

ឯព្រះអាទិត្យនឹងព្រះចន្ទទាំងពីរនេះ រមែងរះឡើងភ្លឺរុងរឿងបានតែតាមពេល តាមវេលា. ព្រះអាទិត្យរះឡើងភ្លឺរុងរឿងបានតែក្នុងវេលាថ្ងៃដល់វេលាយប់ងងឹតវិញ. ព្រះចន្ទ្រពេញបូណ៌មីរះឡើងភ្លឺរុងរឿងបានតែក្នុងវេលាយប់ ដល់ វេលាថ្ងៃ ងងឹតវិញ. ព្រះអាទិត្យនឹងព្រះចន្ទដែលអាចរះឡើងបានតាមពេលតាមវេលានោះ សោតទៀត.ព្រោះតែគ្មានសភាវៈអ្វីដទៃចូលមកបិទបាំងរាំងរា ប្រសិនបើមាន ខ្យល់ព្យុះភ្លៀងផ្គរ មេឃស្រទំចុះអ័ព្ទបែកផ្សែងភ្លៀងបង្អុរ ធ្លាក់ ចុះមកកាល ណាហើយ រស្មីព្រះអាទិត្យព្រះចន្ទ្រានោះឯង នឹងវិនាសបាត់ទៅ ទាំងអស់ អាចនឹងញុំាងលោកទាំងមូលឱ្យងងឹតសូន្យសុងទៅក្នុងកាលនោះដោយពិត ។

**៣. តថាគតប្បវេទិតំ ពុទ្ធវចនំ** ពុទ្ធវចនៈគឺធម៌នឹង វិន័យដែលព្រះតថា គតបានត្រាស់ដឹងហើយ ទ្រង់សំដែងតែងតាំងទុកមកឱ្យជាប្រទីបពន្លឺដល់សត្វលោក ។ អាចយកប្រទីបពន្លឺគឺ ធម៌នឹងវិន័យនោះមកបញ្ចាំងឆ្លុះបំភ្លឺ មើលហេតុពិតនឹង មិនពិត នឹងអំពើល្អអាក្រក់ គុណទោស ខុសត្រូវឱ្យឃើញជាក់ច្បាស់ហើយត្រលប់ ក្រឡាស់ញុំាងចិត្តឱ្យងាកបែរចេញចាកហេតុដែលមិនពិត នឹងអំពើអាក្រក់ ប្រកបដោយទោសនោះឱ្យស្រឡះចេញចាកសន្តានហើយ នឹងបានកាន់ យកតែហេតុដែលពិតអំពើដែលល្អប្រកបដោយគុណនោះ មក ប្រព្រឹត្ត ប្រតិបត្តិតាមជាប្រយោជន៍ប្រពៃក្នុងលោកនេះនឹងលោកខាងមុខដោយពិត ។

ចំណែកខាងធម៌និងវិន័យនេះ ដែលនឹងរុងរឿងទៅបាន លុះតែអាស្រ័យដោយអំណាចឥស្សរជនជួយឧបត្ថម្ភទំនុកបំរុងផង នឹងកុលបុត្រអ្នកសិក្សារៀនសូត្រកុះករចេះដឹងជាច្រើន ហើយខំព្យាយាមបង្ហាត់បង្ហាញសិស្សានុសិស្សតៗគ្នា ទៅផង ទើបអាចនឹងញ៉ាំងព្រះពុទ្ធសាសនាឱ្យរុងរឿងឋិតថេរទៅបាន ។

មួយទៀត បុគ្គលជាធម្មកថិកដែលចេះដឹងហើយ ក៏ពុំបានបិទបាំងរាំងរាឃាត់ហាមដល់អ្នកដទៃឡើយ ហើយខំព្យាយាមខ្វល់ខ្វាយរំលឹកដាស់តឿនអ្នកដទៃឱ្យខំសង្វាតទន្ទេញសិក្សារៀនសូត្រចេះចាំស្ទាត់ហើយប្រព្រឹត្តប្រតិបត្តិតាមឱ្យសមគួរតាមពុទ្ធវចនៈ ។

មួយវិញទៀត បើបុគ្គលជាធម្មកថិកក្តី មិនមែនជាធម្មកថិកក្តីឃាត់ហាមសាសនារបស់ព្រះពុទ្ធ ឬបុគ្គលអ្នកចេះដឹងហើយកំណាញ់ធម៌លាក់លៀមចំណេះវិជ្ជា មិនចង់ឱ្យអ្នកដទៃគេចេះដឹងផង ខ្លាចខាតលាភសក្ការៈរបស់ខ្លួនក្តី បុគ្គលបែបនេះបានឈ្មោះថា បិទបាំងប្រទីបពន្លឺគឺធម៌និងវិន័យរបស់ព្រះសម្មាសម្ពុទ្ធ ឱ្យស្រអាប់បាត់ពន្លឺរស្មីវិនាសសូន្យទៅ ជាហេតុនឹងដឹកនាំមនុស្សទាំងពួងឱ្យវង្វេងភ័ន្តគំនិតសំគាល់ខុសថាត្រូវ សំគាល់ត្រូវថាខុសវិញដោយច្រើន ដូចជាព្រះអាទិត្យ នឹងព្រះចន្ទ្ររះឡើងកំពុងមានពន្លឺរស្មីល្អ ហើយមានសភាវៈដទៃមានរាហុអសុរិន្ទជាដើម ចូលមកបៀតបៀនជ្រៀតជ្រែកបិទបាំង ព្រះអាទិត្យនឹងព្រះចន្ទ្រកាលណាហើយ ពន្លឺរស្មីដែលកំពុងរុងរឿងល្អនោះ ក៏នឹងស្រអាប់បាត់ពន្លឺវិនាសសូន្យទៅមួយរំពេចក្នុងកាលនោះឯង ឯធម៌និងវិន័យ

របស់ព្រះសម្មាសម្ពុទ្ធ ក៏ដូច្នោះដែរ ។

## ធម៌ ៥ យ៉ាង

ជាអង្គនៃធម្មកថិកលោកអ្នកសំដែងនូវធម៌ ដល់ជនទាំងឡាយដទៃជាពុទ្ធភាសិតដែលព្រះបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់សំដែងចំពោះព្រះអានន្ទជាពុទ្ធុបដ្ឋាក មានក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាតថា "ម្នាលអានន្ទ កិរិយានឹងសំដែងនូវធម៌ដល់ជនទាំងឡាយដទៃ មិនមែនជាការងាយទេ ក្រពេកណាស់ព្រោះធម្មកថិកអ្នកសំដែងលុះតែបានញុំាងធម៌ ទាំង ៥ ប្រការឱ្យតាំងនៅក្នុងខ្លួនជាមុន ទើបសំដែងធម៌ដល់ជនដទៃបានមិនមានទោស ។

ឯធម៌ទាំង ៥ ប្រការជាអង្គនៃធម្មកថិកនោះ គឺ :

**១. អនុបុព្វិកថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** ធម្មកថិក ត្រូវសំដែងធម៌ដល់អ្នកដទៃដោយតាំងចិត្តថា អាត្មាអញនឹងសំដែងធម្មកថាជាលំដាប់គឺសីលជាលំដាប់នៃទាន ស្ថានសួគ៌ជាលំដាប់នៃសីលជាដើម នឹង សំដែងធម៌ទៅតាមសមគួរដល់សូត្រ នឹងគាថានោះ ៗ ។

**២. បរិយាយំ ទស្សាមិ កថំ កថេស្សមីតិ បរេសំ ធម្មោទេសេតព្វោ** ធម្មកថិកត្រូវសំដែងធម៌ដល់អ្នកដទៃដោយតាំងចិត្តថាអាត្មាអញនឹងឱ្យបរិយាយគឺ ចង្អុលបង្ហាញប្រាប់ហេតុនៃអត្ថនោះ ៗ ហើយសំដែងធម្មកថា ។

**៣. អនុទ្ទយតំ បដិច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** ធម្មកថិក ត្រូវសំដែងធម៌ដល់អ្នកដទៃដោយ តាំងចិត្ត ថាអាត្មាអញនឹង សំដែង ធម្មកថា អាស្រ័យសេចក្ដីអនុគ្រោះដោយ មេត្តាចិត្តចំពោះ

សព្វ សត្វពុំ រើសមុខ គឺមានបំណងនឹងដោះសត្វដែល ជាប់ ជំពាក់ដោយ សេចក្ដីចង្អៀត ចង្អល់ធំ ឱ្យរួចផុតពីសេចក្ដីចង្អៀតចង្អល់ចិត្ត ។

**៤. ន អាមិសន្តរោ កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** ធម្មកថិកត្រូវសំដែងធម៌ដល់អ្នកដទៃដោយ តាំងចិត្តថាអាត្មាអញ មិនមាន អាមិសជាហេតុ គឺមិនប្រាថ្នានូវលាភគឺ បច្ច័យទាំង៤ ហើយ សំដែងនូវធម្មកថា ។

**៥. អត្តានញ្ច បរញ្ច អនុបហច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ** ធម្មកថិកត្រូវសំដែងធម៌ដល់អ្នកដទៃដោយតាំងចិត្តថា អាត្មាអញ មិនបានបៀត បៀនខ្លួនឯងផង[១] មិនបានបៀតបៀន អ្នកដទៃ ផង[២] ហើយ សំដែងនូវធម្ម កថា ។

ធម្មកថិកអ្នកសំដែងធម៌ ត្រូវញ៉ាំងធម៌ទាំង ៥ នេះឱ្យតាំងនៅក្នុងខ្លួន ជាមុនហើយសឹមសំដែងធម៌ទូន្មានប្រដៅអ្នកដទៃជាខាងក្រោយ ទើបអាច ញ៉ាំងព្រះពុទ្ធសាសនាឱ្យរុងរឿងបានដោយពិត ។

---

(១) ពាក្យថា មិនបានបៀតបៀនខ្លួនឯង គឺមិនពោលសរសើរលើកខ្លួនឯងថាគ្រាន់បើជាអ្នកដទៃ ជាដើម ។

(២) ពាក្យថាមិនបានបៀតបៀនអ្នកដទៃ គឺមិនពោលបន្តុះបង្អាប់អ្នកដទៃថាពុំប្រសើរ ស្មើនឹងខ្លួន ជាដើម ។

## អនេសនាទិ

កិច្ចមានមិនសំដែងធម៌ មិនបង្រៀនធម៌ មិនអធិប្បាយពន្យល់ធម៌ ដល់ជនទាំងឡាយដទៃជាដើម ជាហេតុឱ្យប្រព្រឹត្តទៅដើម្បីញុំាងព្រះពុទ្ធសាសនាឱ្យវិនាសសាបសូន្យ ពុទ្ធភាសិតសំដែងថាមាន ៥ យ៉ាងដូចបាលីថា :

**បញ្ចិមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ** "ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ ប្រការនេះតែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស សាបសូន្យនៃព្រះសទ្ធម្ម" កតមេបញ្ច "ធម៌ ៥ ប្រការ (នោះ) គឺអ្វីខ្លះ ?

**១. ឥធ ភិក្ខវេ ភិក្ខូ ន ធម្មំ បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភូតធម្មំ វេទល្លំ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនា នេះមិនរៀនធម៌គឺ សុត្តៈ, គេយ្យៈ, វេយ្យាករណៈ, គាថា, ឧទានៈ, ឥតិវុត្តកៈ, ជាតកៈ, អព្ភូតធម្មៈ, វេទល្លៈ[១] ។

**២. ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន បរេសំ ទេសេន្តិ** ភិក្ខុទាំងឡាយ មិនសំដែងធម៌ តាមដែលខ្លួនស្តាប់តាមដែលខ្លួនរៀនដល់អ្នក ដទៃ ដោយពិស្តារ ។

---

[១] ពីត្រឹមសុត្តៈ ដល់វេទល្លៈ ហៅថានវង្គសត្ថុសាសនៈ សាសនារបស់ព្រះសាស្តាមានអង្គ ៩ ។

[illegible]